# អនុសញ្ញាអន្តរជាតិ ស្តីពី
# សិទ្ធិជនពិការ



MOSALVY

Disability Action Council

UNICEF

OHCHR

# អនុសញ្ញា ស្តីពី សិទ្ធិជនពិការ
# និង
# ពិធីសារបន្ថែម

អនុសញ្ញាជាភាសាខ្មែរនេះ ជាការកែសំរួលលើការបកប្រែដែលបាន
ធ្វើដោយជនពិការ ដែលធ្វើការជាមួយអង្គការ Jesuit Refugee Service ។

ខែ សីហា ឆ្នាំ ២០០៧

# អនុសញ្ញា ស្តីពី សិទ្ធិជនពិការ

## សេចក្តីផ្តើម

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបញ្ជាក់ថា " មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ " ។ ជនពិការក៏ដូចជាមនុស្សជាតិទាំងអស់ដែរ ត្រូវទទួលបានសិទ្ធិមនុស្សដូចគ្នា "ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ" ។ គោលការណ៍សមភាព និងការមិនរើសអើងត្រូវបានបញ្ជាក់ជាថ្មីនៅរាល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ។ ជាយថាហេតុ រាល់សន្ធិសញ្ញាសិទ្ធិមនុស្សការពារសិទ្ធិជនពិការ ។ ជនពិការត្រូវទទួលបានយ៉ាងពេញលេញនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាថាជនពិការទាំងអស់អាចទទួលបានសិទ្ធិរបស់ខ្លួនដោយមិនមានការរើសអើងនោះ មិនមែនជាការងាយស្រួលឡើយ ទោះជាមានការការពារដោយសន្ធិសញ្ញាដែលមានជាធរមានក្តី ជនពិការនៅតែប្រឈមមុខនឹងឧបសគ្គជាច្រើន ក្នុងការចូលរួមជាសមាជិកដោយស្មើភាពនៅក្នុងសង្គមនិងទទួលរងការរំលោភបំពានលើសិទ្ធិមនុស្សរបស់ពួកគេ នៅគ្រប់ទិសទីលើពិភពលោក ។ ដោយហេតុនេះ ទើបនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសន្ធិសញ្ញាអន្តរជាតិថ្មីមួយ ដែលមានបំណងជាពិសេសលើកស្ទួយសិទ្ធិជនពិការនិងធានាថា ជនពិការមានសិទ្ធិស្មើគ្នាជាមួយជនដទៃទៀត ដែលមានកាយសម្បទាគ្រប់គ្រាន់ពាក់ព័ន្ធនឹងការការពារសិទ្ធិពួកគេ ។

មាត្រា៣នៃអនុសញ្ញានេះបង្កើតសំណុំមួយនៃគោលការណ៍ទូទៅដូចជា :

ក- ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គលរួមទាំងសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល ។

ខ- ការមិនរើសអើង។

គ- ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងការដាក់បញ្ចូលទៅក្នុងសង្គម។

ឃ- ការគោរពជនពិការគ្រប់ប្រភេទ ហើយត្រូវទទួលស្គាល់ថា ជនពិការជាចំណែកនៃភាពចំរុះគ្នារបស់មនុស្ស និងមនុស្សជាតិ។

ង- ឱកាសស្មើភាពគ្នា។

ច- ការបង្កលក្ខណៈងាយស្រួលដល់ជនពិការ។

ឆ- សមភាពរវាងបុរសនិងស្ត្រី។

ជ- ការគោរពសមត្ថភាពរីកចំរើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ។

គោលការណ៍ទូទៅទាំងនេះ បង្កើតជាមូលដ្ឋានដែលអនុសញ្ញានេះខិតខំដោះស្រាយពីសេចក្តីត្រូវការជាក់ស្តែងរបស់ជនពិការ។

មាត្រា៥ ចែងអំពីសិទ្ធិគ្មានការរើសអើង និងភាពស្មើគ្នាដោយផ្តោតជាពិសេសលើជនពិការ និងអនុញ្ញាតជាពិសេសចំពោះការរើសអើងវិជ្ជមានមួយចំនួន ប្រសិនជាចាំបាច់ ដើម្បីពន្លឿនឬធ្វើអោយបានសំរេចនូវភាពស្មើគ្នាតាមព្រឹត្តន័យរបស់ជនពិការ។

បន្ទាប់មក អនុសញ្ញានេះចែងពីគោលការណ៍ណែនាំទូទៅពីវិស័យដែលជាកង្វល់

ជាក់ស្ដែង ចំពោះការការពារសិទ្ធិមនុស្សរបស់ជនពិការ ។ មាត្រា៦ ចែងអំពីស្ថានភាពស្រ្តីពិការ រួមទាំងបញ្ហានៃការរើសអើងជាច្រើន និងបន្ថែម ការការពារដែលមាន នៅក្នុងអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ ស្រដៀងគ្នានេះដែរ មាត្រា៧ ពង្រឹងកិច្ចការពារថែមទៀត ចំពោះកុមារពិការក្នុងមាត្រា២៣នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ។ មាត្រា៨ លើកស្ទួយការយល់ដឹង ដើម្បីប្រយុទ្ធប្រឆាំងនឹងការយល់ឃើញជាអវិជ្ជមាន និងការរើសអើង លើកស្ទួយ ការគោរពសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ជនពិការ និងទទួលស្គាល់ការរួមវិភាគទានជាវិជ្ជមាន ដែលជនពិការធ្វើសំរាប់សង្គម ។ មាត្រា៩ ធានាការពារជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ទទួលបាននូវបរិដ្ឋានជុំវិញខ្លួន ការដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង និងគ្រឿងផាសុបករណ៍ និងសេវាកម្មដទៃទៀត នៅកន្លែងដែលជនពិការរស់នៅ ដូច្នេះហើយ ពួកគេអាចរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅ ។ មាត្រា១១ ចែងអំពីស្ថានការណ៍នៃគ្រោះថ្នាក់ជាពិសេសចំពោះជនពិការ រួមទាំងជំលោះប្រដាប់អាវុធ ជំនួយបន្ទាន់ខាងមនុស្សធម៌ និងគ្រោះធម្មជាតិ ។

បន្ទាប់មក អនុសញ្ញានេះគូសបញ្ជាក់ពីសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គម កិច្ចយ៉ាងជាក់លាក់ ដែលបានទទួលស្គាល់ក្នុងសន្ធិសញ្ញាដទៃទៀតក្នុងទស្សនវិស័យខាងជនពិការ ។ សិទ្ធិទាំងនេះ រួមមានសិទ្ធិរស់រានមានជីវិត ការទទួលស្គាល់ស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ សេរីភាព និងសន្តិសុខបុគ្គល សេរីភាពរួចផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងសេរីភាពរួចផុត

ពីការធ្វើអាជីវកម្ម អំពើហឹង្សា និងការរំលោភបំពាន ការការពារបូរណភាពរូបកាយ សេរីភាពក្នុងការដើរហើរ និងមានសញ្ជាតិ ការរស់នៅដោយឯករាជ្យ និងការដាក់បញ្ចូលទៅក្នុងសហគមន៍ ការចល័តជាបុគ្គល សេរីភាពក្នុងការសំដែងមតិនិងយោបល់ និងសិទ្ធិទទួលបានព័ត៌មាន ការគោរពសិទ្ធិឯកជន សិទ្ធិ មានលំនៅដ្ឋាននិងសិទ្ធិមានគ្រួសារ សិទ្ធិទទួលបានការអប់រំ សុខភាព សិទ្ធិមានក៏រិតជីវភាពរស់នៅសមរម្យ និងការការពារផ្នែកសង្គមកិច្ច ការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម ការរកការងារធ្វើ និងការចូលរួមក្នុងជីវភាពសាធារណៈនិងនយោបាយ ជីវភាពវប្បធមិ  ការកំសាន្ត ការឈប់សំរាក និងកីឡា ។

អនុសញ្ញានេះ មានបទបញ្ញត្តិលំអិតអំពីការអនុវត្តន៍ និងការឃ្លាំមើលថ្នាក់ជាតិ រួមមានការប្រមូលស្ថិតិ និងទិន្នន័យដទៃទៀត និងមុខងារនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសំរេចតាមនិយាមដែលជាបំណងប្រាថ្នារបស់អនុសញ្ញានេះ សំរាប់ជាប្រយោជន៍ដល់ជនពិការ ។ ទន្ទឹមនឹងទិសដៅដែលបានកំណត់ក្នុងអនុសញ្ញានេះ មានតំលៃនិងចាំបាច់ បទេសជាច្រើន នឹងត្រូវប្រឈមមុខពុះពារគ្រប់ឧបសគ្គដ៏ធំធេង ដើម្បីបំពេញនូវការបន្តប្តេជ្ញាចិត្តរបស់ខ្លួនស្របតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ។ ដើម្បីជួយរដ្ឋនានាក្នុងការអនុវត្តន៍អនុសញ្ញានេះឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការដែលស្គាល់ថាជាគណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ នឹងត្រូវបង្កើតឡើងនៅពេលដែលសន្ធិសញ្ញានេះចូលជាធរមាន ។ រដ្ឋភាគីនីមួយៗ ត្រូវបានតម្រូវឱ្យដាក់ជូនរបាយការណ៏មួយតាមកាលកំណត់ទៅគណៈកម្មាធិការនេះ ដោយកំណត់ពីវិធានការដែលត្រូវមាន ដើម្បីអនុវត្តអនុសញ្ញានេះ ។ បន្ទាប់មក គណៈកម្មាធិការ

ត្រូវផ្តល់ការណែនាំ និងអនុសាសន៍ជំនាញ ចំពោះការចាត់វិធានការបន្តទៅទៀត ដើម្បីពង្រឹងការបន្តប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ចំពោះគោលដៅទាំងឡាយដែលបានកំណត់ដោយអនុសញ្ញានេះ ។

ជនពិការត្រូវបានប្រឈមមុខជាមួយឧបសគ្គជាច្រើន ក្នុងការទាមទារសិទ្ធិរបស់ពួកគេ ។ អាស្រ័យហេតុនេះ ទើបពិធីសារបន្ថែមលើអនុសញ្ញានេះបានផ្តល់សមត្ថកិច្ចបន្ថែមដល់គណៈកម្មាធិការនេះ ដើម្បីធ្វើការស៊ើបសួរ និងពិចារណាលើបណ្តឹងរបស់បុគ្គលពាក់ព័ន្ធនឹងការអនុវត្តន៍អនុសញ្ញានេះ ក្នុងប្រទេសទាំងឡាយដែលបានជ្រើសរើសទទួលយកនីតិវិធីនេះ ។

អនុសញ្ញានេះនឹងចូលជាធរមានក្នុងច្បាប់អន្តរជាតិ នៅពេលដែលប្រទេសចំនួនម្ភៃបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ពីបំណងចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញានេះ នៅពេលដ៏ឆាប់ តាមដែលអាចធ្វើទៅបាន ។ យើងសង្ឃឹមថាកម្ពុជា ក៏នឹងផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញានេះផងដែរ ។ នៅពេលដែលរដ្ឋាភិបាលធ្វើដូច្នេះ សិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញានេះនឹងត្រូវបានធានាការពារដោយច្បាប់អន្តរជាតិ និងដោយរដ្ឋធម្មនុញ្ញកម្ពុជាតាមមាត្រា៣១ ។

សេចក្តីព្រាងច្បាប់ស្តីពីជនពិការ ដែលរដ្ឋាភិបាលបានរៀបចំធ្វើជាច្រើនឆ្នាំមកហើយៗបានតាក់តែងតម្រូវតាមស្ថានការណ៍ជាក់ស្តែងក្នុងប្រទេសកម្ពុជា នឹងការពារបន្ថែមទៀតដល់សិទ្ធិជនពិការនៅប្រទេសកម្ពុជា ។

ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៧

# បុព្វកថា

**រដ្ឋភាគីចំពោះអនុសញ្ញានេះ :**

*១- ដោយរំលឹកឡើងវិញ* ពីគោលការណ៍ទាំងឡាយ ដែលមានចែងក្នុង ធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលទទួលស្គាល់សេចក្តីថ្លៃថ្នូរ តំលៃ សិទ្ធិស្មើគ្នា និងសិទ្ធិដែលមិនអាចលក់ដូរបានដែលមានពីកំណើតរបស់មនុស្សគ្រប់ រូបក្នុងសង្គម ថាជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*២- ដោយទទួលស្គាល់ថា* តាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិមនុស្ស អង្គការសហប្រជាជាតិបានប្រកាស និងបាន យល់ព្រមថា មនុស្សគ្រប់រូបមានសិទ្ធិ ទទួលបានសិទ្ធិ និង សេរីភាពគ្រប់បែបយ៉ាង ដូចដែលមានចែងក្នុងសេចក្តីប្រកាសជាសកល និងក្នុងកតិកាសញ្ញាអន្តរជាតិទាំងនេះ ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ ។

*៣- ដោយគូសបញ្ជាក់ឡើងវិញថា* សកលភាព ភាពមិនអាចបំបែកបាន ភាពពំនាក់អាស្រ័យគ្នា និង ភាពទាក់ទងគ្នានៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ទាំងអស់ ព្រមទាំងសេចក្តីត្រូវការរបស់ជនពិការ ត្រូវបានធានាយ៉ាងពេញលេញ ដោយគ្មានការរើសអើង ។

*៤- ដោយរំលឹងឡើងវិញពី* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទំរង់នៃការប្រកាន់ពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការលុប

បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក  អនុសញ្ញាស្តីពីសិទ្ធិកុមារ និង អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់កម្មករទេសន្តប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ។

*៥- ដោយទទួលស្គាល់ថា* ពិការភាព គឺជាទស្សនៈដែលមានការវិវត្ត ហើយពិការភាពកើតចេញពីអន្តរ កម្មរវាងជនពិការ និងឧបសគ្គទាំងឡាយទាក់ទងទៅនឹងអាកប្បកិរិយា និងបរិយាកាសជុំវិញដែលរារាំងពួកគេមិន ឱ្យចូលរួមក្នុងសង្គមបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ ។

*៦- ដោយទទួលស្គាល់*ពីសារៈសំខាន់នៃគោលការណ៍ និងសេចក្តីណែនាំពីគោលនយោបាយ ដែលមាននៅក្នុងកម្មវិធីសកម្មភាពពិភពលោកទាក់ទងនឹងជនពិការ និងនៅក្នុងវិធានបទដ្ឋាននានាស្តីពីការផ្តល់ឱកាសស្មើគ្នា ដល់ជនពិការក្នុងការចូលរួមលើកស្ទួយបង្កើត និងវាយតំលៃពីគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាព ផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ ដើម្បីផ្តល់ឱកាសឱ្យបានស្មើគ្នាថែមទៀត ដល់ជនពិការ ។

*៧- ដោយគូសបញ្ជាក់*ពីសារៈសំខាន់នៃការបញ្ជ្រាបបញ្ហាពិការភាព ថាជាផ្នែកមួយពេញលេញនៃយុទ្ធសាស្ត្រពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តភាព ។

*៨- ដោយទទួលស្គាល់ផងដែរថា* ការរើសអើងប្រឆាំងនឹងបុគ្គលណាមួយ

ដោយសារតែពិការភាព គឺជាការរំលោភលើសេចក្តីថ្លៃថ្នូរ និងតំលៃរបស់មនុស្ស ដែលមានពីកំណើត ។

*៩- ដោយទទួលស្គាល់បន្ថែមទៀត* ពីពិការភាពផ្សេងគ្នារបស់ជនពិការ ។

*១០- ដោយទទួលស្គាល់*ពីតម្រូវការលើកស្ទួយ និងការពារសិទ្ធិមនុស្សរបស់ជនពិការគ្រប់រូប រួមទាំងអ្នកទាំងឡាយណាដែលត្រូវការគាំពារកម្រិតខ្ពស់ ។

*១១- ដោយមានការបារម្ភថា* បើទោះជាមានឧបករណ៍ និងការធានារ៉ាប់រងផ្សេងៗយ៉ាងនេះក្តី ក៏ជនពិការនៅតែបន្តប្រឈមមុខនឹងឧបសគ្គ ក្នុងការចូលរួមរបស់គេដោយស្មើភាពគ្នាជាមួយសមាជិកឯទៀតក្នុងសង្គម និងការរំលោភសិទ្ធិមនុស្សរបស់ពួកគេនៅទូទាំងពិភពលោក ។

*១២- ដោយទទួលស្គាល់*ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីលើកកម្ពស់ស្ថានភាពរស់នៅរបស់ជនពិការនៅគ្រប់ប្រទេស ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

*១៣- ដោយទទួលស្គាល់*ពីវិភាគទានដ៏មានតំលៃ និងមានសក្តានុពលដែលនៅតែមានអត្ថិភាពរបស់ជនពិការ ចំពោះសុខុមាលភាពទាំងស្រុង និងភាពប្លែកៗគ្នា នៃសហគមន៏របស់ខ្លួន ។ ការរួមវិភាគទានទាំងនេះ គឺជាការលើកស្ទួយជនពិកាឱ្យទទួល-បានពេញលេញនូវសិទ្ធិមនុស្សនិងសេរីភាពជាសារវន្ត និងការចូលរួមយ៉ាងពេញលេញរបស់ពួកគេក្នុងសង្គម ហើយជាលទ្ធផលបានលើកកម្ពស់សតិអារម្មណ៏របស់ជនពិការថាជាផ្នែកមួយនៃសង្គម និងភាពជឿនលឿនដ៏មានខ្លឹមសារក្នុងការអភិវឌ្ឍន៏មនុស្សសង្គមកិច្ច និងសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រ ។

*១៤- ដោយទទួលស្គាល់*ពីសារៈសំខាន់នៃស្វ័យភាពជាឯកត្តបុគ្គល និងឯក-រាជ្យភាពរបស់ជនពិការម្នាក់ៗ រួមទាំងសេរីភាពក្នុងការមានជំរើសរបស់ខ្លួនផ្ទាល់ ។

*១៥- ដោយយល់ឃើញថា* ជនពិការគួរតែមានឱកាសចូលរួមយ៉ាងសកម្ម ក្នុងដំណើរការធ្វើសេចក្តីសម្រេច អំពីគោលនយោបាយ និងកម្មវិធីនានា រួមទាំងវិស័យផ្សេងទៀតដែលពាក់ព័ន្ធនឹងបញ្ហារបស់ពួកគេផ្ទាល់ ។

*១៦- ដោយមានក្តីកង្វល់អំពី*ស្ថានភាពលំបាកដែលជនពិការបានជួបប្រទះនូវការរើសអើងជាច្រើន ឬការរើសអើងដែលមានទំរង់ធ្ងន់ធ្ងរ ដោយឈរលើមូលដ្ឋាននៃការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយ ឬទស្សនៈផ្សេងទៀត ជាតិ ជាតិពន្ធុ ប្រភពដើមជនជាតិនិងសង្គម ទ្រព្យសម្បត្តិ ដើមកំណើត អាយុ ឬឋានៈផ្សេងៗទៀត ។

*១៧- ដោយទទួលស្គាល់ថា* ស្ត្រីនិងកុមារីពិការ តែងតែជួបប្រទះនូវភយន្តរាយធំជាងគេ ទាំងក្នុងនិងក្រៅផ្ទះ ដូចជាអំពើហឹង្សា ការបង្ករបួសស្នាម ឬការបំពាន ការមិនអើពើ ឬការមិនស្និទ្ធស្នាល អំពើធ្វើទុក្ខបុកម្នេញ ឬការកេងប្រវ័ញ្ច ។

*១៨- ដោយទទួលស្គាល់ថា* កុមារពិការគួរតែបានទទួលយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារដទៃ និង *ដោយរំលឹកឡើងវិញពី*កាតព្វកិច្ចដែលត្រូវសម្រេចឱ្យបាននូវគោលដៅទាំងនេះរបស់រដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

*១៩- ដោយគូសបញ្ជាក់ពី*តម្រូវការដើម្បីដាក់បញ្ចូលទស្សនៈវិស័យផ្នែកយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីលើកស្ទួយជនពិការឱ្យទទួលបាន

ពេញលេញនូវសិទ្ធិមនុស្សនិងសេរីភាពជាសារវន្ត ។

*២០- ដោយគូសបញ្ជាក់ពី*ការពិតដែលថាជនពិការភាគច្រើនរស់នៅក្នុងស្ថានភាពក្រីក្រ ហើយស្ថិតក្នុង ស្ថានភាពបែបនេះ *ដោយទទួលស្គាល់ពី*តម្រូវការជាចំបង ដើម្បីលើកឡើងពីផលប៉ះពាល់ជា អវិជ្ជមាននៃភាពក្រីក្រ ដល់ជនពិការ ។

*២១- ដោយចងចាំថា* លក្ខខណ្ឌសន្តិភាព និងសន្តិសុខដែលផ្អែកលើមូលដ្ឋាននៃការគោរពយ៉ាងពេញលេញ នូវគោលបំណង និងគោលការណ៍ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងការប្រតិបត្តិតាមលិខិតុបករណ៍ សិទ្ធិមនុស្សដែលនៅមានជាធរមាន គឺជាប្រការសំខាន់ណាស់ ដើម្បីការការពារឱ្យបានពេញលេញដល់ជនពិការជាពិសេស នៅពេលមានជំលោះប្រដាប់អាវុធ និងការចូលកាន់កាប់របស់បរទេស ។

*២២- ដោយទទួលស្គាល់ពី*សារៈសំខាន់នៃការទទួលបាននូវការសំរួលផ្នែកវប្បធម៌ សេដ្ឋកិច្ច សង្គមកិច្ច កាយសម្បទា សុខភាព ការអប់រំ និង ព័ត៌មាននិងទំនាក់ទំនងដើម្បីជួយឱ្យជនពិការអាចទទួលបានយ៉ាងពេញលេញ នូវសិទ្ធិមនុស្សនិងសេរីភាពជាសារវន្តទាំងអស់ ។

*២៣- ដោយយល់ច្បាស់ថា* បុគ្គលម្នាក់ៗ ដែលមានកាតព្វកិច្ចចំពោះអ្នកដទៃនិងចំពោះសហគមន៍របស់ខ្លួន ត្រូវមានការទទួលខុសត្រូវ ដើម្បីខិតខំប្រឹងប្រែងក្នុងការលើកស្ទួយ និងការប្រតិបត្តិតាមសិទ្ធិទាំងឡាយដែលមានចែង នៅក្នុងធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្ស ។

*២៤- ដោយមានជំនឿថា* គ្រួសារគឺជាធាតុបង្កដ៏សំខាន់ និងតាមធម្មជាតិនៃសង្គម ហើយមានសិទ្ធិទទួលបាននូវការការពារពីសង្គមនិងរដ្ឋ ។ ដោយជឿជាក់ថា

ជនពិការ និងសមាជិកក្រុមគ្រួសាររបស់គេគួរទទួលបាននូវ ការការពារ និងការជួយជ្រោមជ្រែងជាចាំបាច់ ដើម្បីឱ្យក្រុមគ្រួសារគេអាចចូលរួមចំណែក ធ្វើឱ្យជនពិការទទួលបានសិទ្ធិដោយស្មើភាពគ្នា និងដោយពេញលេញ ។

*២៥- ដោយមានជំនឿថា* អនុសញ្ញាអន្តរជាតិរួមនិងទូលំទូលាយមួយ ដើម្បីការពារនិងលើកស្ទួយសិទ្ធិ និង សេចក្ដីថ្លៃថ្នូររបស់ជនពិការ នឹងរួមវិភាគទានយ៉ាងថ្លៃថ្លា ក្នុងការកែតម្រូវគុណវិបត្តិសង្គមដ៏ជ្រាលជ្រៅចំពោះជនពិការ និងលើកស្ទួយជនពិការឱ្យមានឱកាសស្មើគ្នា ក្នុងការចូលរួមលើវិស័យពលរដ្ឋ នយោបាយសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ ទាំងក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្ដាអារ្យប្រទេស ។

**បានព្រមព្រៀងគ្នាដូចតទៅ :**

## មាត្រា ១ : គោលបំណង

គោលបំណងនៃអនុសញ្ញានេះ គឺដើម្បីលើកស្ទួយការពារនិងធានាឱ្យជនពិការទទួលបានដោយពេញលេញ នូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ និងដើម្បីលើកស្ទួយការគោរពសេចក្ដីថ្លៃថ្នូរដែលមានពីកំនើតមករបស់ជនពិការ ។

ជនពិការសំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទាផ្លូវចិត្ត ប្រាជ្ញា ឬវិញ្ញាណ ដែលនៅពេលជួបប្រទះជាមួយឧបស័គ្គនានាអាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

**មាត្រា ២ : និយមន័យ**

សំរាប់គោលបំណងនៃអនុសញ្ញានេះ :

**១- ទំនាក់ទំនង:**រាប់បញ្ចូលទាំងភាសា ការបង្ហាញជាអត្ថបទ អក្សរស្ទាប ទំនាក់ទំនងដោយការស្ទាប ការបោះពុម្ពជាអក្សរធំៗ ប្រព័ន្ធព័ត៌មានចំរុះដែលអាចទទួលបាន ព្រមទាំងសំណេរ ខ្សែអាត់សំលេង ភាសា សាមញ្ញៗ ឧបករណ៍បកស្រាយទិន្នន័យព័ត៌មានអំពីមនុស្ស និងវិធីអំណះអំណាង និងជំនួសផ្សេងៗ មធ្យោបាយ និងទំរង់នានានៃការទំនាក់ទំនង រួមទាំងព័ត៌មានដែលអាចទទួលបាន និងបច្ចេកវិទ្យាទំនាក់ទំនង ។

**២- ភាសា:** រួមបញ្ចូលទាំងភាសានិយាយ ភាសាសញ្ញា និងទំរង់ផ្សេងទៀតនៃភាសាដែលមិនប្រើក្នុងការនិយាយ ។

**៣- ការរើសអើងដោយសារពិការភាព:** មានន័យថា ការបែងចែក ការផាត់-ចេញ ឬការដាក់កំហិតណាមួយ ដោយសារតែពិការភាព ដែលមានបំណង ឬមានអានុភាពធ្វើឱ្យចុះទន់ខ្សោយ ឬគ្មានការទទួលស្គាល់ ការអនុវត្តន៍ ឬការទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀត ។ ការរើសអើងនេះ រាប់បញ្ចូលរាល់ទំរង់នៃការរើសអើង រួមទាំងការបដិសេធនូវដំណោះស្រាយដ៏សមហេតុផលផង ។

**៤- ដំណោះស្រាយដ៏សមហេតុផល:** មានន័យថា ការកែប្រែ និងការកែតម្រូវឱ្យសមរម្យនិងចាំបាច់ មិនធ្វើ ឱ្យការទទួលខុសត្រូវមានភាពអសមាមាត្រ ឬមិន

ត្រឹមត្រូវ ដែលតម្រូវតែក្នុងករណីពិសេស ដើម្បីធានាដល់ជនពិការ ឱ្យទទួលបាន និង អនុវត្តបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋាន ស្មើភាពគ្នាជាមួយអ្នកដទៃ។

**៥- ការរចនាប្លង់ជាសាកល** មានន័យថា ការគូសប្លង់ផលិតផល បរិស្ថាន កម្មវិធី និងសេវាកម្មផ្សេងៗ ដែលមនុស្សគ្រប់រូបអាចប្រើប្រាស់បានដោយមិនទាមទាចំពោះការសំរបតាម ឬគំរោងប្លង់ពិសេសផ្សេងទៀត ក្នុងវិសាលភាពធំបំផុត ដែលអាចធ្វើបាន។ "**ការរចនាប្លង់ជាសាកល** " មិនត្រូវផាត់ចោលឧបករណ៍ជំនួយទាំងឡាយសំរាប់ក្រុមជនពិការដោយឡែកដែលត្រូវការឧបករណ៍ជំនួយទាំងនេះទេ។

**មាត្រា ៣ : គោលការណ៍ទូទៅ**

គោលការណ៍ទូទៅនៃអនុសញ្ញានេះមានដូចជា :

ក- ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំងសេរីភាពក្នុងការជ្រើសរើសដោយ ខ្លួនឯង ផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល។

ខ- ការមិនរើសអើង។

គ- ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធិភាព និងការដាក់បញ្ចូលទៅក្នុងសង្គម។

ឃ- ការគោរពជនពិការគ្រប់ប្រភេទ ហើយត្រូវទទួលស្គាល់ថាជនពិការជាចំណែកនៃភាពចំរុះគ្នារបស់មនុស្ស និងមនុស្សជាតិ។

ង- ឱកាសស្មើភាពគ្នា។

ច- ការបង្កលក្ខណៈងាយស្រួលដល់ជនពិការ ។

ឆ- សមភាពរវាងបុរស និងស្ត្រី ។

ជ- ការគោរពសមត្ថភាពរីកចំរើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ ។

**មាត្រា ៤ : កាតព្វកិច្ចទូទៅ**

១- រដ្ឋភាគីត្រូវធានា និងលើកស្ទួយសមិទ្ធិពេញលេញនៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់សំរាប់ជនពិការ ដោយគ្មានការរើសអើងចំពោះពិការភាពណាមួយឡើយ ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋភាគីត្រូវរ៉ាប់រង:

ក- អនុម័តរាល់វិធានការផ្លូវច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតដែលសមស្រប ដើម្បីអនុវត្តនូវសិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ ។

ខ- ចាត់រាល់វិធានការសមស្រប រួមទាំង វិធានការនីតិកម្ម ដើម្បីកែប្រែ ឬលុបចោលច្បាប់ បទបញ្ជា ទំនៀមទំលាប់ និងការអនុវត្តន៏ជាក់ស្តែងដែលនៅជាធរមាន ហើយដែលបង្កើតការរើសអើងប្រឆាំងនឹងជនពិការ ។

គ- យកចិត្តទុកដាក់ដល់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្សរបស់ជនពិការ នៅរាល់គោលនយោបាយ និងកម្មវិធីទាំងអស់ ។

ឃ- ទប់ស្កាត់ពីការចូលរួមក្នុងអំពើ ឬការអនុវត្តន៏ណាមួយដែលមិនស្របនឹងអនុសញ្ញានេះ ហើយធានាថា អាជ្ញាធរ និងស្ថាប័នសារធារណៈនានា អនុវត្តស្របតាម

អនុសញ្ញានេះ ។

ង- ចាត់វាល់វិធានការសមស្រប ដើម្បីលុបបំបាត់ការរើសអើងដោយសារតែពិការភាពពីបុគ្គលណាម្នាក់ ពីអង្គការ ឬស្ថាប័នឯកជនណាមួយ ។

ច- ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ និងអភិវឌ្ឍន៍ការរចនាប្លង់ជាសកលនៃទំនិញ សេវាកម្ម សំភារៈ និងគ្រឿងបរិក្ខារ ដូចមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ដែលគួរតម្រូវឱ្យជនពិការសំរបតាមជាអប្បបរមាតាម តែអាចធ្វើបាន និងមានតំលៃថោក ដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់ពួកគេ ក្នុងបំណងលើកស្ទួយការប្រើប្រាស់ និងភាពអាចរកបាននូវរបស់ទាំងអស់ខាងលើនេះ និងដើម្បីលើកស្ទួយការរចនាប្លង់ជាសកល ក្នុងការអភិវឌ្ឍន៍ បទដ្ឋាន និងគោលការណ៍ណែនាំ ។

ឆ- ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ ការអភិវឌ្ឍន៍ ការប្រើប្រាស់ និងភាពអាចរកបាននៃបច្ចេកវិទ្យាថ្មីៗ រួមទាំងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ជំនួយចល័ត ឧបករណ៍និងបច្ចេកវិទ្យាជំនួយ ដែលសមស្របសំរាប់ជនពិការ ដោយផ្តល់អាទិភាពដល់បច្ចេកវិទ្យានូវតំលៃសមរម្យ ។

ជ- ផ្តល់ឱ្យជនពិការនូវលទ្ធភាពទទួលបានព័ត៌មានអំពី ជំនួយចល័ត ឧបករណ៍ និងបច្ចេកវិទ្យាជំនួយ រួមទាំងបច្ចេកវិទ្យាថ្មីៗ ទំរង់ផ្សេងៗទៀតនៃជំនួយ សំភារៈ និងសេវាកម្មជួយគាំពារដទៃទៀត ។

ឈ- លើកស្ទួយការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបុគ្គលិកធ្វើការជាមួយជនពិការពីសិទ្ធិដែលត្រូវបានទទួលស្គាល់ក្នុងអនុសញ្ញានេះ ដើម្បីផ្តល់សេវាកម្ម និងជំនួឱ្យកាន់តែប្រសើរថែមទៀត ដែលត្រូវធានាដោយសិទ្ធិទាំងនោះ ។

២- អនុលោមតាមសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគីត្រូវចាត់វិធានការតាមធនធានដែលខ្លួនមាន ជាអតិបរមា និងតាមការចាំបាច់ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងគោលបំណងសម្រេចឱ្យបានជាបន្តបន្ទាប់ នូវសមិទ្ធិដ៏ពេញលេញនៃសិទ្ធិទាំងនេះ ដោយគ្មានធ្វើឱ្យខូចខាតដល់កាតព្វកិច្ចទាំងឡាយដែលមានចែងនៅ ក្នុងអនុសញ្ញានេះដែលត្រូវតែអនុវត្តភ្លាម១ស្របតាមច្បាប់អន្តរជាតិ ។

៣- ក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍ច្បាប់ និងគោលនយោបាយនានា ដើម្បីអនុវត្តអនុសញ្ញានេះ និងក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចផ្សេងទៀត ស្តីពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជនពិការ រដ្ឋភាគីត្រូវពិគ្រោះយោបល់យ៉ាងជិតស្និទជាមួយជនពិការដែលពាក់ព័ន្ធយ៉ាងសកម្ម រួមទាំងកុមារពិការ តាមរយៈអង្គការតំណាងរបស់ពួកគេ ។

៤- គ្មានបទបញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ នឹងប៉ះពាល់ដល់បទបញ្ញត្តិផ្សេងទៀត ដែលកំពុងតែរួមវិភាគទានយ៉ាងច្រើនដល់ការសម្រេចបានសិទ្ធិទាំងឡាយរបស់ជនពិការ និងដែលអាចមានចែងនៅក្នុងច្បាប់របស់រដ្ឋភាគី ឬច្បាប់អន្តរជាតិដែលនៅជាធរមានបញ្ញត្តិចំពោះរដ្ឋនោះទេ។ រដ្ឋភាគីមិនត្រូវដាក់កំហិត ឬដកហូតសិទ្ធិណាមួយនៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តដែលត្រូវបានទទួលស្គាល់ ឬនៅមានជាធរមានក្នុងរដ្ឋភាគីណាមួយនៃអនុសញ្ញានេះទេ ដោយអនុលោមទៅតាមច្បាប់អនុសញ្ញានានា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា អនុសញ្ញានេះ មិនទទួលស្គាល់សិទ្ធិ ឬសេរីភាពបែបនេះឡើយ ឬក៏ថាខ្លួនគ្រាន់តែទទួលស្គាល់សិទ្ធិ

និងសេរីភាពទាំងនេះក្នុង វិសាលភាពមួយតូចជាងនេះ ។

៥- បទបញ្ញត្តិនៃអនុសញ្ញានេះ ត្រូវមានវិសាលភាពគ្របដណ្តប់ដល់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកំណត់ ឬការលើកលែងណាមួយឡើយ ។

**មាត្រា ៥ : សមភាព និងការមិនរើសអើង**

១- រដ្ឋភាគីទទួលស្គាល់ថា មនុស្សទាំងអស់ស្មើភាពគ្នាចំពោះមុខច្បាប់ ហើយមានសិទ្ធិទទួលបានដោយគ្មាន ការរើសអើងណាមួយដល់ការការពារស្មើគ្នា និងផលប្រយោជន៍នៃច្បាប់ស្មើគ្នា ។

២- រដ្ឋភាគី ត្រូវហាមឃាត់រាល់ការរើសអើងដោយសារតែពិការភាព និងធានាដល់ជនពិការ ពីការការពារតាមផ្លូវច្បាប់ស្មើគ្នា និងមានប្រសិទ្ធិភាព ប្រឆាំងនឹងការរើសអើងតាមគ្រប់រូបភាព ។

៣- ដើម្បីលើកស្ទួយសមភាព និងលុបបំបាត់ការរើសអើង រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានានូវការផ្តល់ដំណោះស្រាយសមហេតុផល ។

៤- វិធានការជាក់លាក់ដែលចាំបាច់ ដើម្បីបង្កើនល្បឿន ឬធ្វើឱ្យបានសម្រេចតាមព្រឹត្តិហេតុ នូវសមភាពរបស់ជនពិការ មិនត្រូវចាត់ទុកជាការរើសអើង តាមអត្ថន័យដែលមានចែងនៅក្នុងអនុសញ្ញានេះទេ ។

**មាត្រា ៦ : ស្ត្រីពិការ**

១- រដ្ឋភាគីទទួលស្គាល់ថា ស្ត្រីនិងកុមារីពិការងាយរងការរើសអើងច្រើនបែប-យ៉ាង ចំពោះបញ្ហានេះ ត្រូវចាត់វិធានការនានា ដើម្បីធានាឱ្យពួកគេទទួលបានភាព-

ស្មើគ្នា និងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ។

២- រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាឱ្យស្ត្រីទទួលបានការអភិវឌ្ឍន៍ វឌ្ឍនភាព និងការផ្ដល់សិទ្ធិអំណាចឱ្យបានពេញលេញ ក្នុងគោលបំណងដើម្បីធានាពួកគេឱ្យអនុវត្ត និងទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តដូចមានចែងនៅក្នុងអនុសញ្ញានេះ ។

**មាត្រា ៧ : កុមារពិការ**

១-រដ្ឋភាគីត្រូវចាត់វាល់វិធានការចាំបាច់នានា ដើម្បីធានាឱ្យកុមារពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារដទៃ ។

២- នៅគ្រប់សកម្មភាពដែលទាក់ទងនឹងកុមារពិការ ឧត្តមប្រយោជន៍របស់កុមារពិការ ត្រូវលើកយកមកពិចារណាមុនគេ ។

៣- រដ្ឋភាគីត្រូវធានាថាកុមារពិការមានសិទ្ធិបញ្ចេញមតិរបស់ខ្លួនដោយសេរីពីបញ្ហាគ្រប់បែបយ៉ាងដែលប៉ះពាល់ដល់ពួកគេ ។ ទស្សនៈរបស់ពួកគេត្រូវទទួលបានការពិចារណាថ្លឹងថ្លែងឱ្យបានសមស្របទៅនឹងអាយុ និង ភាពចាស់ទុំរបស់ពួកគេដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារដទៃ ហើយពួកគេត្រូវទទួលបាននូវការជួយជ្រោមជ្រែងសមស្របទៅនឹងពិការភាព និងអាយុរបស់ពួកគេ ដើម្បីឱ្យពួកគេទទួលបាននូវសិទ្ធិនេះយ៉ាងពិតប្រាកដ ។

**មាត្រា ៨ ៖ ការលើកកម្ពស់ការយល់ដឹង**

១- រដ្ឋភាគីត្រូវអនុម័តជាបន្ទាន់ នូវវិធានការសមស្រប និងមានប្រសិទ្ធិភាព ដូចខាងក្រោម ៖

ក- លើកកម្ពស់ការយល់ដឹងអំពីជនពិការ ក្នុងសង្គមជាតិទាំងមូល រួមទាំងនៅតាមគ្រួសារ និងលើកតំកើងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ ។

ខ- ប្រយុទ្ធប្រឆាំងនឹងការរើសអើង ការប្រកាន់ពូជសាសន៍ និងការប្រព្រឹត្តមិនសមរម្យផ្សេងៗដល់ជនពិការ រួមទាំងសកម្មភាពរើសអើងទាំងឡាយទាក់ទងនឹងភេទ និងអាយុ ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត ។

គ- លើកស្ទួយការយល់ដឹងពីសមត្ថភាព និងការរួមវិភាគទានដល់ជនពិការ ។

២- វិធានការទាំងឡាយដើម្បីសម្រេចបាននូវគោលបំណងនេះរួមមាន ៖

ក- ផ្តួចផ្តើមនិងរក្សាយុទ្ធនាការការយល់ដឹងជាសាធារណៈប្រកបដោយប្រសិទ្ធភាពតាមការគ្រោងទុក ៖

i. បណ្តុះបណ្តាល ផ្សព្វផ្សាយសិទ្ធិជនពិការឱ្យបានយល់ដឹង និងទទួលការគាំទ្រ ។

ii. លើកស្ទួយការយល់ឃើញជាវិជ្ជមាន និងការយល់ដឹងពីសង្គមកាន់តែទូលាយចំពោះជនពិការ ។

iii. លើកស្ទួយការទទួលស្គាល់ពីជំនាញ គុណសម្បត្តិនិងលទ្ធភាពរបស់ជនពិការ និងទទួលស្គាល់ពីការរួមវិភាគទានរបស់ជនពិការ នៅទីកន្លែងធ្វើការ និងនៅទីផ្សារការងារ ។

ខ- លើកតំកើងនៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំ រួមទាំងកុមារគ្រប់អាយុទាំងអស់ ពីឥរិយាបថមួយចេះគោរព សិទ្ធិរបស់ជនពិការ ។

គ- ជំរុញគ្រប់ស្ថាប័នព័ត៌មាន ឱ្យផ្សព្វផ្សាយពីជនពិការក្នុងលក្ខណៈមួយ ស្របទៅតាមគោលបំណងនៃ អនុសញ្ញានេះ ។

ឃ- លើកស្ទួយកម្មវិធីបណ្តុះបណ្តាលការយល់ដឹង អំពីជនពិការ និង សិទ្ធិរបស់ជនពិការ ។

**មាត្រា ៩ ៖ ការបន្ថុលក្ខណៈងាយស្រួល**

១- ដើម្បីជួយជនពិការឱ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញ ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត រដ្ឋភាគីត្រូវចាត់វិធាការសមស្រប ដើម្បីធានាដល់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃទទួលបាននូវបរិស្ថានជុំវិញមធ្យោ-បាយធ្វើដំណើរ ព័ត៌មាននិងទំនាក់ទំនង រួមទាំងប្រព័ន្ធនិងបច្ចេកវិទ្យាព័ត៌មាន និង ទំនាក់ទំនង គ្រឿងសំរួល និងសេវាកម្មផ្សេងទៀតដែលបើកចំហ ឬផ្តល់ឱ្យប្រើប្រាស់ ជាសាធារណៈ ទាំងនៅទីក្រុងទាំងនៅតាមទីជនបទដាច់ស្រយាល ។ ដោយត្រូវរួម បញ្ចូលនូវអត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គ និងរបាំងទាំងឡាយដល់ការ ទទួលបាននូវសិទ្ធិទាំងនេះ វិធានការទាំងនេះត្រូវអនុវត្តចំពោះ ៖

ក- អាគារ ផ្លូវថ្នល់ មធ្យោបាយធ្វើដំណើរ និងគ្រឿងសំរួលក្នុងផ្ទះ និងក្រៅផ្ទះ ផ្សេងទៀត រួមទាំងសាលារៀន លំនៅដ្ឋាន គ្រឹះស្ថានសុខាភិបាល និងកន្លែងការងារ ។

ខ- ព័ត៌មានទំនាក់ទំនង និងសេវាកម្មដទៃទៀតរួមទាំងសេវាកម្មអេឡិចត្រូនិច

និងសេវាកម្មសង្គ្រោះបន្ទាន់ ។

២- រដ្ឋភាគីត្រូវចាត់វិធានការសមស្របផងដែរដើម្បី ៖

ក- តាក់តែង ប្រកាសឱ្យប្រើ និងតាមដានការអនុវត្តន៍ នៃគោលការណ៍ណែនាំ និងបទដ្ឋានអប្បបរមា សំរាប់ការទទួលបាននូវគ្រឿងសំរួលនិងសេវាកម្មដែលបើកចំហ និងផ្តល់ឱ្យសាធារណៈជន ។

ខ- ធានាថា អង្គភាពឯកជនដែលផ្តល់សេវាកម្ម និងគ្រឿងសំរួលដែលបើកចំហ ឬផ្តល់ឱ្យសាធារណៈជន ត្រូវពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយពីការបង្កលក្ខណៈងាយស្រួលដល់ជនពិការ ។

គ- ផ្តល់ការបណ្តុះបណ្តាលដល់ស្ថាប័នពាក់ពន្ធ័ ពីការបង្កលក្ខណៈងាយស្រួយ និងលទ្ធភាពចេញចូល ដែលជនពិការកំពុងជួបប្រទះ ។

ឃ- ដាក់ស្លាកសញ្ញាជាអក្សរស្ទាប និងជាទំរង់ងាយអាន ងាយយល់នៅតាមអគារ និងទីកន្លែងសាធារណៈដទៃទៀត ។

ង- ផ្តល់ទម្រង់នៃជំនួយផ្ទាល់ និងអន្តរការី រួមបញ្ចូលអ្នកនាំផ្លូវ អ្នកជំនាញអាន និងអ្នកបកប្រែភាសាសញ្ញា អាជីព ដើម្បីបង្កភាពងាយស្រួលដល់ការប្រើប្រាស់អគារ និងទីកន្លែងសាធារណៈផ្សេងទៀតបាន ។

ច- លើកស្ទួយទំរង់នៃការជួយ និងការគាំពារសមស្របដទៃទៀត ដល់ជនពិការ ដើម្បីធានាថា ពួកគេទទួលបាននូវព័ត៌មាន ។

ឆ- លើកស្ទួយជនពិការ ឱ្យទទួលបាននូវប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន និង

ទំនាក់ទំនងថ្មីៗ រួមទាំងអ៊ិនធឺណេតផង ។

ជ- លើកស្ទួយការរចនាបួង់ ការអភិវឌ្ឍន៍ផលិតកម្ម និងការចែកចាយនៃប្រព័ន្ធនិងបច្ចេកវិទ្យាព័ត៌មាន ដែលអាចទទួលបាននៅតំណាក់ដំបូង ដូច្នេះប្រព័ន្ធនិងបច្ចេកវិទ្យាទាំងនេះនឹងមានតំលៃថោកល្មមអាចទទួលយកបាន ។

**មាត្រា ១០ : សិទ្ធិរស់រានមានជីវិត**

រដ្ឋភាគីអះអាងជាថ្មីថា មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិតចាប់តាំងពីកំណើតមក និងត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីធានាឱ្យជនពិការទទួលបានដោយប្រសិទ្ធិភាព និងស្មើភាពគ្នាជាមួយអ្នកដទៃទៀតដែរ ។

**មាត្រា ១១ : ស្ថានភាពគ្រោះថ្នាក់ និងការសង្គ្រោះបន្ទាន់ផ្នែកមនុស្សធម៌**

អនុលោមតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋភាគីត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីធានាដល់ការការពារ និងសុវត្ថិភាពរបស់ជនពិការ ក្នុងស្ថានភាពគ្រោះថ្នាក់ រួមទាំងស្ថានភាពមានជំលោះប្រដាប់អាវុធ ការសង្គ្រោះបន្ទាន់ផ្នែកមនុស្សធម៌ និងការកើតឡើងនៃគ្រោះមហន្តរាយធម្មជាតិ ។

**មាត្រា ១២ : ការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់**

១- រដ្ឋភាគីអះអាងជាថ្មីថា ជនពិការមានសិទ្ធិត្រូវបានទទួលស្គាល់ នៅគ្រប់ទីកន្លែងទាំងអស់ថាជាមនុស្សនៅ ចំពោះមុខច្បាប់ ។

២- រដ្ឋភាគីត្រូវទទួលស្គាល់ថា ជនពិការមានសមត្ថភាពខាងផ្នែកច្បាប់ ដោយ

ឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត ។

៣- រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីផ្តល់លទ្ធភាពឱ្យជនពិការទទួលបានការជួយឧបត្ថម្ភ ដែលពួកគេអាចត្រូវការក្នុងការអនុវត្តន៍សមត្ថភាពផ្នែកច្បាប់របស់ខ្លួន ។

៤- រដ្ឋភាគីត្រូវធានាថា វិធានការទាំងអស់ដែលពាក់ព័ន្ធនឹងការអនុវត្តន៍សមត្ថភាពខាងផ្នែកច្បាប់ ផ្តល់នូវការការពារយ៉ាងសមរម្យ និងមានប្រសិទ្ធភាពដើម្បីទប់ស្កាត់ការបំពាន អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ការការពារបែបនេះត្រូវធានាថា វិធានការទាំងឡាយដែលទាក់ទងនឹងការអនុវត្តន៍សមត្ថភាពខាងផ្នែកច្បាប់ គោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់ជនពិការ ត្រូវបានរួចផុតពីទំនាស់ផលប្រយោជន៍ និងឥទ្ធិពលមិនត្រឹមត្រូវ ត្រូវតែសមាមាត្រ និងបន្ថែមបន្ថយទៅតាមកាលៈទេសៈរបស់ជនពិការ អនុវត្តក្នុងរយៈពេលខ្លីបំផុត តាមដែលអាចធ្វើទៅបាន និងត្រូវបានត្រួតពិនិត្យជាទៀងទាត់ដោយអាជ្ញាធរ មានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀងមួយឬស្ថាប័នតុលាការ ។ ការការពារទាំងនេះ ត្រូវតែសមាមាត្រទៅនឹងកម្រិតដែលវិធានការបែបនេះ មានផល ប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ជនពិការ ។

៥- អនុលោមតាមបទបញ្ញត្តិនៃមាត្រានេះ រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានាឱ្យជនពិការមានសិទ្ធិស្មើគ្នា ក្នុងការធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ ឬទទួលមរតក ក្នុងការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនផ្សេងៗ និងមានសិទ្ធិស្មើគ្នាចំពោះការខ្ចីឥណទានធនាគារ ការបញ្ចាំ និងទំរង់ផ្សេងៗ

ទៀតនៃ ឥណទាន ហិរញ្ញវត្ថុ ហើយត្រូវធានាថា ជនពិការមិនត្រូវបានគេដកហូត យកទ្រព្យសម្បត្តិតាមអំពើចិត្តនោះទេ ។

**មាត្រា ១៣ : សិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌**

១- រដ្ឋភាគីត្រូវធានាពីសិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌ដែលមានប្រសិទ្ធភាព សំរាប់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រួមទាំងតាមរយៈ បទបញ្ញត្តិនៃដំណោះស្រាយសមស្របតាមអាយុ និងតាមនីតិវិធី ដើម្បីជួយសំរួល តួនាទីដ៏មានប្រសិទ្ធភាពរបស់ពួកគេ ទោះក្នុងនាមជាអ្នកចូលរួមដោយផ្ទាល់ឬដោយ ប្រយោលក្តី រួមទាំងធ្វើជាសាក្សីនៅរាល់ចំណាត់ការរឿងក្តី រួមទាំងនៅតំណាក់ការ ស៊ើបអង្កេត និងតំណាក់កាលដំបូងៗផ្សេងទៀត ។

២- ដើម្បីជួយធានាពីសិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌ដែលមានប្រសិទ្ធភាពសំរាប់ ជនពិការ រដ្ឋភាគីត្រូវលើកស្ទួយការបណ្តុះបណ្តាលឱ្យបានសមស្របដល់អ្នកទាំងឡាយ ដែលកំពុងបំរើការងារក្នុងវិស័យយុត្តិធម៌ រួមទាំងនគរបាល និងបុគ្គលិកពន្ធនាគារផង ។

**មាត្រា ១៤ : សេរីភាព និងសន្តិសុខបុគ្គល**

១- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រដ្ឋភាគីត្រូវធានាថា ជនពិការ :

ក- មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

ខ- មិនត្រូវបានដកហូតសេរីភាពរបស់ពួកគេដោយខុសច្បាប់ ឬតាមទំនើងចិត្ត ឡើយ ហើយធានាថា ការដកហូតសេរីភាពណាមួយត្រូវតែអនុលោមទៅតាមច្បាប់ និងធានាថា គ្មានការដកហូតសេរីភាព ដោយសំអាងលើពិការភាពទោះក្នុងករណីណា

ក៏ដោយ ។

២- រដ្ឋភាគីត្រូវធានាថា ប្រសិនបើជនពិការត្រូវបានដកហូតសេរីភាព ទោះតាមនីតិវិធីណាក៏ដោយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ជនពិការមានសិទ្ធិទទួលបាននូវការធានារ៉ាប់រង អនុលោមទៅតាមច្បាប់ សិទ្ធិមនុស្ស អន្តរជាតិ ហើយការប្រព្រឹត្តចំពោះជនពិការត្រូវស្របតាមគោលបំណង និង គោលការណ៍នៃអនុសញ្ញានេះ រួមទាំងតាមបទបញ្ញត្តិនៃដំណោះស្រាយ ដ៏សមហេតុ ផលផង ។

**មាត្រា ១៥ : សេរីភាពចាកផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក**

១- គ្មាននរណាម្នាក់ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ ។ ជាពិសេស គ្មាននរណាម្នាក់ ត្រូវទទួលរងនូវការធ្វើពិសោធន៍វេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយ គ្មានការស្ម័គ្រចិត្ត យល់ព្រមពីសាមីខ្លួនឡើយ ។

២- រដ្ឋភាគី ត្រូវចាត់វាល់វិធានការតាមផ្លូវច្បាប់ ផ្លូវរដ្ឋបាល ផ្លូវតុលាការ ឬ វិធានការដទៃទៀតឱ្យមានប្រសិទ្ធិភាព ដើម្បីការពារជនពិការឱ្យរួចចាកផុតពីការ ធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ដោយឈរលើមូលដ្ឋានមួយស្មើភាពគ្នាជាមួយអ្នកដទៃ ។

**មាត្រា ១៦ ៖ សេរីភាពចាកផុតពីការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន**

១- រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របតាមផ្លូវច្បាប់ រដ្ឋបាល សង្គម អប់រំ និងវិធានការដទៃទៀត ដើម្បីការពារជនពិការទាំងក្នុងផ្ទះទាំងក្រៅផ្ទះ ពីគ្រប់ទំរង់នៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន រួម ទាំងទិដ្ឋភាពនានាដោយឈរលើមូលដ្ឋានយេនឌ័ររបស់ពួកគេផង ។

២- រដ្ឋភាគីក៏ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីទប់ស្កាត់គ្រប់ទំរង់នៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន ដោយធានាឱ្យមានទំរង់សមស្របនៃការជួយឧបត្ថម្ភ និងការគាំទ្រដែលឆ្លើយតបបានទៅនឹងតម្រូវការតាមអាយុ និងយេនឌ័រដល់ជនពិការ ក្រុមគ្រួសារ និងអ្នកថែទាំរបស់គេ រួមទាំងតាមរយៈការផ្តល់ព័ត៌មាននិងការអប់រំ អំពីវិធីចៀសវាង ទទួលស្គាល់ និងរាយការណ៍យ៉ាងដូចម្តេចពីករណីនានានៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន ។ រដ្ឋភាគីត្រូវធានាថា សេវាកម្មការពារទាំងឡាយត្រូវមានលក្ខណៈឆ្លើយតបទៅតាមតម្រូវការនៃអាយុយេនឌ័រនិងពិការភាព ។

៣- ដើម្បីទប់ស្កាត់ការកើតឡើងនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពានតាមគ្រប់រូបភាព រដ្ឋភាគីត្រូវធានាថា កម្មវិធី និងគ្រឿងបរិក្ខារគ្រប់បែបយ៉ាងដែលរចនាឡើងដើម្បីបំរើជនពិការ ត្រូវបានត្រួតពិនិត្យយ៉ាងម៉ត់ចត់បំផុត ដោយអាជ្ញាធរឯករាជ្យ ។

៤- រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប ដើម្បីលើកស្ទួយការធ្វើឱ្យប្រសើរឡើងវិញខាងផ្លូវចិត្ត បញ្ញា និងកាយសម្បទា ការស្តារនីតិសម្បទា និងការធ្វើ

សមាហរណកម្មចូលក្នុងសង្គមជាតិវិញនៃជនពិការ ដែលជាជនរងគ្រោះពីទំរង់ណាមួយនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន រួមទាំងតាមរយៈការផ្តល់សេវាកម្មការពារ ។ ការធ្វើឱ្យប្រសើរឡើងវិញ និងការធ្វើសមាហរកម្មឡើងវិញបែបនេះ ត្រូវកើតឡើងក្នុងបរិយាកាសមួយ ដែលទ្រទ្រង់ដល់សុខភាព សុខុមាលភាព ការគោរពបុគ្គល សេចក្តីថ្លៃថ្នូរ និងស្វ័យភាពរបស់បុគ្គល និងត្រូវគិតគូរដល់ តម្រូវការជាក់ស្តែង តាមអាយុនិងយេនឌ័រ ។

៥- រដ្ឋភាគីត្រូវបង្កើតច្បាប់ និងគោលនយោបាយឱ្យមានប្រសិទ្ធភាព រួមទាំងច្បាប់ និងគោលនយោបាយដែលផ្តោតការយកចិត្តទុកដាក់ដល់ស្ត្រី និងកុមារ ដើម្បីធានាថាករណីនៃការកេងប្រវ័ញ្ច អំពើហិង្សានិងការរំលោភបំពានលើជនពិការត្រូវបានកំណត់មុខសញ្ញា ស៊ើបអង្កេត និងកាត់ទោសឱ្យបានត្រឹមត្រូវ ។

**មាត្រា ១៧ : ការការពារភាពសុចរិតនៃបុគ្គល**

ជនពិការគ្រប់រូប មានសិទ្ធិប្រកាន់យកភាពសុច្ចរិតរបស់ខ្លួនទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

**មាត្រា ១៨ : សេរីភាពនៃការធ្វើដំណើរ និងការទទួលបានសញ្ជាតិ**

១- រដ្ឋភាគីត្រូវទទួលស្គាល់សិទ្ធិរបស់ជនពិការ ចំពោះសេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងការជ្រើសរើសទីលំនៅរបស់ខ្លួន និងមានសញ្ជាតិ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រួមទាំងការធានាឱ្យជនពិការដូចខាងក្រោមៈ

ក- មានសិទ្ធិទទួលបាន និងប្តូរសញ្ជាតិ ហើយមិនត្រូវដកហូតសញ្ជាតិរបស់

ពួកគេដោយមិនសមហេតុផល ឬដោយសារតែពិការភាពនោះទេ ។

ខ- មិនត្រូវដកហូតលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានកាន់កាប់ និង ប្រើប្រាស់ឯកសារសញ្ជាតិ ឬអត្តសញ្ញាណប័ណ្ណរបស់ពួកគេ ឬក្នុងការប្រើប្រាស់និតិវិធីពាក់ព័ន្ធនានា ដូចជានីតិវិធីអន្តោរប្រវេសន៍ជាដើមដោយសារតែពិការភាពនោះទេ ដែលពួកគេអាចត្រូវការ ដើម្បីសំរួលដល់ការអនុវត្តសិទ្ធិមានសេរីភាពក្នុងការធ្វើដំណើរ ។

គ- មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសកំណើតរបស់ខ្លួនផងដែរ ។

ឃ- មិនត្រូវដកហូតសិទ្ធិចូលក្នុងប្រទេសរបស់ខ្លួន ដោយមិនសមហេតុផល ឬដោយសារតែពិការភាពនោះឡើយ ។

២- កុមារពិការត្រូវបានគេចុះបញ្ជីភ្លាមបន្ទាប់ពីប្រសូត និងត្រូវមានសិទ្ធិពីកំណើតក្នុងការទទួលបានឈ្មោះមួយ សិទ្ធិទទួលបានសញ្ជាតិមួយ និងតាមលទ្ធភាពដែលអាចធ្វើបាន មានសិទ្ធិស្គាល់ឪពុកម្តាយ និងទទួលការថែទាំពីឪពុកម្តាយ ។

**មាត្រា ១៩ : ការរស់នៅដោយឯករាជ្យ និងការដាក់បញ្ចូលក្នុងសហគមន៍**

រដ្ឋភាគីនៃអនុសញ្ញានេះ ទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ជនពិការក្នុងការរស់នៅក្នុងសហគមន៍ ដោយមានជំរើសស្មើភាពគ្នាជាមួយអ្នកដទៃ ហើយត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធភាពដើម្បីជួយឱ្យជនពិការ ទទួលបានយ៉ាងពេញលេញនូវសិទ្ធិនេះ និងការដាក់បញ្ចូល និងការចូលរួមយ៉ាងពេញលេញរបស់ជនពិការ

ក្នុងសហគមន៍ ដោយរួមមានការធានាថា :

ក- ជនពិការទទួលបានឱកាសជ្រើសរើសកន្លែងតាំងទីលំនៅ និងទីកន្លែង និងអ្នកដែលគេត្រូវរស់នៅជាមួយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ និងមិនត្រូវបានគេតម្រូវឱ្យរស់នៅ តាមការរៀបចំជាពិសេសណាមួយឡើយ ។

ខ- ជនពិការមានលទ្ធភាពទទួលបានសេវាកម្មទ្រទ្រង់ការរស់នៅ កន្លែងស្នាក់អាស្រ័យនិងសេវាកម្មទ្រទ្រង់សហគមន៍ផ្សេងៗទៀត រួមទាំងជំនួយបុគ្គលដែលចាំបាច់ដើម្បីទ្រទ្រង់ការរស់នៅ និងការរួមបញ្ចូលទៅក្នុងសហគមន៍ និងបង្ការពីភាពឯកោ ឬការឃ្លាតឆ្ងាយពីសហគមន៍ ។

គ- សេវាកម្ម និងគ្រឿងបរិក្ខាសហគមន៍ សំរាប់ប្រជាពលរដ្ឋទូទៅក៏សំរាប់ជនពិការដែរ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា និងឆ្លើយតបបានទៅនឹងតម្រូវការរបស់ជនពិការ ។

**មាត្រា ២០ : ភាពចល័តផ្ទាល់ខ្លួន**

រដ្ឋភាគីត្រូវចាត់វិធានការមានប្រសិទ្ធភាពនានា ដើម្បីធានាភាពចល័តផ្ទាល់ខ្លួនដោយឯករាជ្យរបស់ជនពិការ តាមលទ្ធភាពដែលអាចធ្វើទៅបានល្អបំផុតដែលរួមមាន :

ក- ការជួយសំរួលភាពចល័តផ្ទាល់ខ្លួនរបស់ជនពិការ ក្នុងលក្ខណៈនិងតាមពេលពេលវេលានៃការជ្រើសរើសរបស់គេ និងមានតំលៃសមរម្យ ។

ខ- ការជួយសំរួលឱ្យជនពិការ មានលទ្ធភាពទទួលបានឧបករណ៍ជំនួយដល់

ភាពចល័តដែលមានគុណភាព គ្រឿងសំភារៈជួយសំរួល បច្ចេកវិទ្យា ទំរង់នៃជំនួយផ្ទាល់ និងអន្តរការី រួមទាំងការធ្វើឱ្យរបស់របរទាំងនេះស្ថិតក្នុងតំលៃសមស្រប ។

គ- ការផ្តល់ការបណ្តុះបណ្តាលជំនាញទាក់ទងនឹងការចល័តដល់ជនពិការ និងដល់បុគ្គលិកឯកទេសដែលធ្វើការ ជាមួយជនពិការ ។

ឃ- ការលើកទឹកចិត្តអង្គភាពនានាដែលផលិតឧបករណ៍ជំនួយដល់ការចល័ត គ្រឿងសំភារៈជួយសំរួល និងបច្ចេកវិទ្យាជំនួយ ឱ្យគិតពិចារណាដល់គ្រប់ទិដ្ឋភាព នៃការចល័តរបស់ជនពិការ ។

**មាត្រា ២១ : សេរីភាពនៃការសំដែងមតិ យោបល់ និងសិទ្ធិទទួលបានព័ត៌មាន**

រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាថា ជនពិការអាចអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនបាន ក្នុងការសំដែងមតិយោបល់ រួមទាំងសេរីភាពក្នុងការស្វែងរកទទួលនិងផ្តល់ព័ត៌មាន និងទស្សនៈដោយឈរលើមូលដ្ឋាន ស្មើភាពគ្នាជាមួយអ្នកដទៃ និងតាមរយៈគ្រប់ទំរង់នៃទំនាក់ទំនងស្របតាមការជ្រើសរើសរបស់គេ ដូចដែលមានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញានេះ តាមរយៈ :

ក- ការផ្តល់ព័ត៌មានសាធារណៈ ឱ្យដល់ជនពិការ តាមទំរង់ និងបច្ចេកវិទ្យាដែលគេអាចទទួលបានសមស្របទៅនឹងប្រភេទផ្សេងៗនៃពិការភាព ឱ្យបានទាន់ពេលវេលា និងគ្មានការបង់ប្រាក់បន្ថែម ។

ខ- ការទទួលនិងជួយសំរួលដល់ការប្រើប្រាស់ភាសាសញ្ញា អក្សរស្ទាបនិងទំនាក់ទំនងផ្សេងៗទៀត ព្រមទាំងគ្រប់មធ្យោបាយ របៀបនិងទំរង់នៃទំនាក់ទំនង

ផ្សេងៗទៀត ដែលអាចទទួលយកបាន តាមការជ្រើសរើសរបស់ជនពិការ ក្នុងការទាក់ទងជាផ្លូវការ ។

គ- ការជំរុញឱ្យអង្គភាពឯកជននានា ដែលផ្តល់សេវាកម្មផ្សេងៗ ដល់សាធារណៈជន រួមទាំងតាមរយៈអ៊ិនធឺណេត ដើម្បីផ្តល់ព័ត៌មាន និងសេវាកម្មផ្សេងៗ តាមទំរង់ដែលជនពិការអាចទទួលបាន និងប្រើប្រាស់បាន ។

ឃ- ការលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមទាំងអ្នកផ្សព្វផ្សាយព័ត៌មានតាមអ៊ិនធឺណេតដើម្បីធ្វើឱ្យជនពិការអាចប្រើប្រាស់សេវាកម្មរបស់ពួកគេបាន ។

ង- ការទទួលស្គាល់ និងការលើកស្ទួយការប្រើប្រាស់ភាសាសញ្ញា ។

**មាត្រា ២២ : ការគោរពសិទ្ធិឯកជន**

១- គ្មានជនពិការណាម្នាក់ ដោយមិនគិតពីកន្លែងរស់នៅ ឬការរៀបចំរបៀបរស់នៅ ត្រូវទទួលរងការជ្រៀតជ្រែកសិទ្ធិឯកជន គ្រួសារ ផ្ទះសំបែង ឬលិខិតឆ្លើយឆ្លង ឬប្រភេទផ្សេងៗទៀតនៃទំនាក់ទំនងរបស់ខ្លួនតាមទំនើងចិត្ត ឬដោយខុសច្បាប់ ឬទទួលរងការបំពារបំពានមិនស្របច្បាប់ដល់កត្តិយស និងកេរ្តិ៍ឈ្មោះរបស់ពួកគេឡើយ ។ ជនពិការមានសិទ្ធិទទួលបានការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការបំពារបំពានទាំងនេះ ។

២- រដ្ឋភាគីត្រូវការពារសិទ្ធិឯកជនរបស់បុគ្គល ព័ត៌មានពីសុខភាព និងស្តារលទ្ធភាពពលកម្មរបស់ជនពិការ ដោយ ឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

**មាត្រា ២៣ ៖ ការគោរពលំនៅដ្ឋាន និងគ្រួសារ**

១- រដ្ឋភាគីត្រូវចាត់វិធានការនានាដែលសមស្រប និងមានប្រសិទ្ធភាព ដើម្បីលុបបំបាត់ចោលការរើសអើង ប្រឆាំងនឹងជនពិការតាមគ្រប់រូបភាពដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ គ្រួសារ មាតាបិតាភាព និងទំនាក់ទំនងសាច់ញាតិ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ធ្វើដូច្នេះដើម្បីធានាថា ៖

ក- ជនពិការគ្រប់រូបដែលដល់អាយុរៀបការ មានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារមួយ ដោយឈរលើមូលដ្ឋានព្រមព្រៀងពេញលេញ និងដោយសេរី ពីអនាគតសហព័ទ្ធ ។

ខ- ជនពិការមានសិទ្ធិធ្វើការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវក្នុងការកំណត់ចំនួនកូន និងចន្លោះ ពេលមានកូន និងក្នុងការទទួលព័ត៌មានសមស្របទៅតាមវ័យ ការអប់រំពីការពន្យាកំណើត និងសុខភាពបន្តពូជ ព្រមទាំងមធ្យោបាយចាំបាច់នានាដែលជួយឱ្យពួកគេអាចអនុវត្តសិទ្ធិទាំងនេះបាន ។

គ- ជនពិការ រួមទាំងកុមារ រក្សាបាននូវតំណពូជរបស់ខ្លួន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

២- រដ្ឋភាគីត្រូវធានាពីសិទ្ធិ និងការទទួលខុសត្រូវរបស់ជនពិការក្នុងការធ្វើជាអាណាព្យាបាលភាព ការគ្រប់គ្រងកុមារ ការបង្កើតមូលនិធិមនុស្សធម៌ ការយកក្មេងមកចិញ្ចឹម ឬស្ថាប័ននានាដែលស្រដៀងគ្នា ដែលទស្សនៈទាំងនេះ មាននៅក្នុងច្បាប់ជាតិ ។ នៅគ្រប់ករណី ឧត្តមប្រយោជន៍របស់កុមារត្រូវតែមានឧត្តមភាព ។ រដ្ឋភាគីត្រូវផ្តល់ជំនួយសមស្របដល់ជនពិការ ក្នុងការបំពេញការទទួលខុសត្រូវ

ចិញ្ចឹមកូនរបស់ពួកគេ ។

៣- រដ្ឋភាគីត្រូវធានាថា កុមារពិការមានសិទ្ធិស្មើគ្នាចំពោះការគោរពដល់ជីវិតគ្រួសារ ។ ដើម្បីធ្វើឱ្យសិទ្ធិទាំងនេះបានសម្រេច និងដើម្បីបង្ការការបិទបាំងការបំបរបង់ ការមិនយកចិត្តទុកដាក់ និងការដាក់កុមារពិការឱ្យនៅឯកោរដ្ឋភាគីត្រូវផ្ដល់ព័ត៌មាន សេវាកម្ម និងការជួយឧបត្ថម្ភដល់កុមារពិការ និងក្រុមគ្រួសាររបស់ពួកគេឱ្យបាន រួសរាន់និងទូលំទូលាយ ។

៤- ដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកឱ្យរស់នៅទីទៃពីឪពុកម្ដាយ ដោយផ្ទុយពីបំណងរបស់គេ ឡើយ លើកលែងតែដោយអាជ្ញាធរមានសមត្ថកិច្ច ដែលសម្រេចដោយការត្រួតពិនិត្យរបស់តុលាការ អនុលោមតាមច្បាប់ និងនីតិវិធីដែលនៅមានជាធរមាន ថាការបំបែកបែបនេះមានលក្ខណៈចាំបាច់ សំរាប់ឧត្ដមប្រយោជន៏របស់កុមារ ។ គ្មានករណីណាដែលកុមារត្រូវបានបំបែកពីឪពុកម្ដាយ ដោយសារតែពិការភាពរបស់កុមារ ឬដោយសារតែ ពិការភាពរបស់ឪពុកឬម្ដាយ ឬដោយសារតែឪពុកម្ដាយពិការទាំងពីរនាក់នោះឡើយ ។

៥- ក្នុងករណីដែលគ្រួសាររបស់កុមារពិការផ្ទាល់មិនអាចបីបាច់ថែរក្សាកុមារពិការបាន រដ្ឋភាគីត្រូវខិតខំគ្រប់បែបយ៉ាង ដើម្បីផ្ដល់ការថែទាំជំនួស ក្នុងរង្វង់គ្រួសារមួយដែលធំជាង ហើយបើមិនបានដូច្នេះទេ គួរតែក្នុងរង្វង់សហគមន៏ មួយដែលមានការរៀបចំជាលក្ខណៈគ្រួសារ ។

**មាត្រា ២៤ : ការអប់រំ**

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការចំពោះការអប់រំ ។ ជាមួយនឹងទស្សនៈដើម្បីធ្វើឱ្យសិទ្ធិនេះបានសម្រេច ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋាននៃការផ្តល់ឱកាសស្មើភាពគ្នា រដ្ឋភាគីត្រូវធានាឱ្យមានប្រព័ន្ធ អប់រំបញ្ចូលគ្នាមួយ នៅគ្រប់កម្រិតសិក្សា និងការសិក្សាពេញមួយជីវិតដែលមានទិសដៅដល់ :

ក- ការអភិវឌ្ឍន៍ទាំងស្រុងនៃសក្តានុពលមនុស្ស សេចក្តីថ្លៃថ្នូរ តំលៃបុគ្គល និងការពង្រឹងការគោរពសិទ្ធិមនុស្ស សេរីភាពជាសារវ័ន្ត និងភាពចំរុះគ្នានៃមនុស្សជាតិ ។

ខ- ការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ ទេពកោសល្យ និងគំនិតច្នៃប្រឌិតរបស់ជនពិការ ក៏ដូចជាសមត្ថភាពខាងកាយសម្បទា និងប្រាជ្ញាស្មារតី ឱ្យដល់សក្តានុពលពេញទំហឹងរបស់ពួកគេ ។

គ- ជួយឱ្យជនពិការចូលរួមយ៉ាងសកម្មក្នុងសង្គមដោយសេរី ។

២- ដើម្បីធ្វើឱ្យសិទ្ធិនេះបានសម្រេច រដ្ឋភាគីត្រូវធានាថា :

ក- ជនពិការមិនត្រូវបានផាត់ចេញពីប្រព័ន្ធអប់រំទូទៅដោយសារតែពិការភាពនោះទេ ហើយកុមារពិការមិនត្រូវបានផាត់ចេញពីការអប់រំដែលខានពុំបាន និងឥតបង់ថ្លៃ នៅកម្រិតបឋម ឬមធ្យមសិក្សា ដោយសារតែ ពិការភាព ។

ខ- ជនពិការអាចទទួលបានការអប់រំរួមគ្នា មានគុណភាព និងមិនបង់ថ្លៃ នៅកម្រិតបឋម និងមធ្យមសិក្សា ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ នៅ

ក្នុងសហគមន៍ដែលគេរស់នៅ ។

គ- ផ្តល់ដំណោះស្រាយសមស្របទៅតាមតម្រូវការរបស់បុគ្គលម្នាក់ៗ ។

ឃ- ជនពិការទទួលបានការឧបត្ថម្ភដែលគេត្រូវការ ក្នុងក្របខ័ណ្ឌប្រព័ន្ធអប់រំទូទៅ ដើម្បីជួយពួកគេឱ្យ ទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព ។

ង- វិធានការជួយឧបត្ថម្ភជាឯកកត្តបុគ្គលដ៏មានប្រសិទ្ធភាព ត្រូវបានផ្តល់ឱ្យក្នុងបរិយាកាសដែលបង្កើនការអភិវឌ្ឍន៍សង្គម និងសិក្សាធិការជាអតិបរមាស្របទៅតាមគោលដៅនៃការដាក់បញ្ចូលយ៉ាងពេញលេញ ។

៣- រដ្ឋភាគីត្រូវជួយជនពិការឱ្យអាចរៀនយកជំនាញអភិវឌ្ឍន៍សង្គម និងបំណិនជីវិត ដើម្បីជួយឱ្យពួកគេចូលរួមបានដោយស្មើភាពគ្នា និងយ៉ាងពេញលេញក្នុងការអប់រំ និងជាសមាជិកនៃសហគមន៍ ។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានារួមមាន ៈ

ក- ជួយសំរួលដល់ការរៀនអក្សរស្ទាប អក្សរជំនួស របៀបនៃការរៀនបែបជំនួយ ព្រមទាំងមធ្យោបាយ និងទំរង់ផ្សេងៗនៃទំនាក់ទំនង ជំនាញនៃការចល័តនិងតំរង់ទិស ព្រមទាំងជួយសំរួលដល់ការគាំទ្រ និងការណែនាំក្រុមជាដៃគូ ។

ខ. ជួយសំរួលដល់ការរៀនភាសាសញ្ញា និងការលើកស្ទួយអត្តសញ្ញាណផ្នែកភាសារបស់សហគមន៍ជនពិការថ្លង់ ។

គ- ធានាថា ការអប់រំសំរាប់ជនពិការ ជាពិសេសកុមារដែលថ្លង់ ពិការភ្នែក ឬពិការភ្នែកហើយថ្លង់ ត្រូវបានធ្វើឡើងក្នុងទំរង់និងភាសា និងមធ្យោបាយទំនាក់ទំនង

សំរាប់ជនពិការម្នាក់ៗ ដ៏សមស្របបំផុត ក្នុងបរិយាកាសដែល បង្កើនការអភិវឌ្ឍន៍សង្គម និងសិក្សាធិការជាអតិបរមា ។

៤- ដើម្បីជួយធានាដល់ការសម្រេចឱ្យបាននូវសិទ្ធិនេះ រដ្ឋភាគីត្រូវចាត់វិធាន-ការសមស្របនានា ដើម្បីផ្តល់ការងារដល់គ្រូបង្រៀន រួមទាំងគ្រូពិការ ដែលមានលក្ខណៈសម្បត្តិក្នុងការបង្រៀនភាសាសញ្ញានិង/ឬអក្សរស្ទាបនិងដើម្បីបណ្តុះបណ្តាលដល់អ្នកជំនាញ និងបុគ្គលិកដែលធ្វើការនៅគ្រប់កម្រិតសិក្សា ។ ការបណ្តុះបណ្តាលបែបនេះ ត្រូវដាក់បញ្ចូលការយល់ដឹងអំពីពិការភាព និងការប្រើប្រាស់ របៀបនៃការរៀនបែបជំនួយ ព្រមទាំងមធ្យោបាយ និងទំរង់ផ្សេងៗនៃទំនាក់ទំនងបច្ចេកទេស និងសំភារៈអប់រំសមស្រប ដើម្បីជួយដល់ជនពិការ ។

៥- រដ្ឋភាគីត្រូវធានាថា ជនពិការអាចទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាជាទូទៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំមនុស្សពេញវ័យ និងការអប់រំពេញមួយជីវិត ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពគ្នា ជាមួយអ្នកដទៃ ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋភាគីត្រូវធានាថា ដំណោះស្រាយសមហេតុផល ត្រូវបានផ្តល់ជូនដល់ជនពិការ ។

**មាត្រា ២៥ ៈ សុខភាព**

រដ្ឋភាគីទទួលស្គាល់ថា ជនពិការមានសិទ្ធិក្នុងការទទួលបាននូវបទដ្ឋានសុខភាពខ្ពស់បំផុត ដោយគ្មានការរើសអើង ដោយសារតែពិការភាពនោះឡើយ ។ រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាដល់ជនពិការឱ្យទទួលបានសេវាកម្មសុខភាពតាមយេនឌ័រ រួមទាំងសុខភាពទាក់ទងនឹងការស្តារនីតិសម្បទា ។ ជាពិសេស

រដ្ឋភាគីត្រូវ ៖

ក- ផ្តល់ដល់ជនពិការនូវឋានៈ គុណភាព និងបទដ្ឋានដូចគ្នានៃកម្មវិធី និងសេវាថែទាំសុខភាព ដោយមិនបង់ប្រាក់ ឬតាមតំលៃមួយសមស្របដូចអ្នកដទៃដែរ រួមទាំងបញ្ហាសុខភាពបន្តពូជនិងផ្លូវភេទ និងកម្មវិធីសុខភាពសាធារណៈជាមូលដ្ឋាន ។

ខ- ផ្តល់សេវាកម្មសុខភាពទាំងនេះ ទៅតាមតម្រូវការរបស់ជនពិការ ដោយផ្តោតជាពិសេសចំពោះពិការភាពរបស់ពួកគេ រួមទាំងការផ្តល់អត្តសញ្ញាណកម្មពីដំបូង និងការធ្វើអន្តរាគមន៍ឱ្យបានរួសរាន់តាមការគួរ និងសេវាកម្មដែលបានរចនាឡើង ដើម្បីបង្ការ និងបន្ថយភាពពិការបន្ថែមទៀតឱ្យបានជាអប្បបរមា រួមទាំងកុមារ និងមនុស្ស ចាស់ ។

គ- ផ្តល់សេវាកម្មសុខភាពទាំងនេះឱ្យបានជិតបំផុតតាមតែអាចធ្វើបានដល់ជនពិការនៅក្នុងសហគមន៍ របស់ខ្លួន រួមទាំងនៅតាមតំបន់ជនបទ ។

ឃ- តម្រូវឱ្យអ្នកមានវិជ្ជាជីវៈសុខភាព ផ្តល់ការថែទាំសុខភាពដល់ជនពិការឱ្យមានគុណភាពដូចគ្នានឹង ការថែទាំអ្នកដទៃ ដោយឈរលើមូលដ្ឋាននៃការយល់ព្រមសេរី និងយកជាការបាន ដោយលើកឡើងពីការយល់ដឹងអំពីសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរស្វ័យភាព និងតម្រូវការរបស់ជនពិការ តាមរយៈការបណ្តុះបណ្តាល និងការប្រកាសពីបទដ្ឋានក្រមសីលធម៌ សំរាប់ការថែទាំសុខភាពសាធារណៈ និងឯកជន ។

ង- ហាមឃាត់ការរើសអើងដល់ជនពិការ ក្នុងការផ្តល់ការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងជីវិត ដែលការធានារ៉ាប់រងបែបនេះត្រូវបានអនុញ្ញាតដោយច្បាប់-ជាតិ និងត្រូវផ្តល់ឱ្យក្នុងលក្ខណៈមួយយុត្តិធម៌ និងសមហេតុផល ។

ច- ទប់ស្កាត់ការបដិសេធដែលមានលក្ខណៈរើសអើង ក្នុងការផ្តល់ការថែទាំសុខភាព ឬសេវាកម្មសុខភាព ឬចំណីអាហារ និងសារធាតុរាវ ដោយសារតែពិការភាព ។

**មាត្រា ២៦ : ការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម**

១- រដ្ឋភាគីត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធិភាព រួមទាំងតាមរយៈការជួយគ្នាជាដៃគូ ដើម្បីឱ្យជនពិការអាចទទួលបាន និងរក្សាបានឯករាជ្យភាពជាអតិបរមា សមត្ថភាពគ្រប់គ្រាន់ខាងវិជ្ជាជីវៈ សង្គមកិច្ច ផ្លូវចិត្ត និងកាយសម្បទា ព្រមទាំងការចូលរួម និងការដាក់បញ្ចូលដោយពេញលេញ នៅក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត ។ ដើម្បីសម្រេចបានគោលដៅនេះ រដ្ឋភាគីត្រូវរៀបចំ ពង្រឹងនិងពង្រីកសេវាកម្ម និងកម្មវិធីនៃការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្មឱ្យបានខ្លាំងក្លា ជាពិសេសក្នុងវិស័យសុខភាព ការងារ ការអប់រំ និងសេវា កម្មសង្គម ។ តាមរបៀបបែបនេះ សេវាកម្ម និងកម្មវិធីទាំងនេះ :

ក- ចាប់ផ្តើមនៅតំណាក់កាលដំបូងបំផុតតាមតែអាចធ្វើបាន ហើយផ្អែកទៅលើការវាយតំលៃដោយវិន័យចំរុះ ពីសេចក្តីត្រូវការនិងចំនុចខ្លាំងរបស់បុគ្គលម្នាក់ៗ ។

ខ- គាំទ្រដល់ការចូលរួម និង ការរាប់បញ្ចូលទៅក្នុងសហគមន៏និងគ្រប់ទិដ្ឋភាពនៃសង្គម ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងបានដល់ដៃជនពិការ នៅកន្លែងដែលជិតសហគមន៏រស់នៅរបស់គេបំផុត រួមទាំងនៅតាមតំបន់ជនបទ ។

២- រដ្ឋភាគីត្រូវលើកស្ទួយការអភិវឌ្ឍន៏ ការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលបន្តដល់អ្នកជំនាញ និងបុគ្គលិកធ្វើការខាងសេវាកម្មនៃការធ្វើឱ្យមាន

លទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម ។

៣- រដ្ឋភាគីត្រូវលើកស្ទួយចំណេះដឹង ការទទួលបាន និងការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាជំនួយផ្សេងៗ ដែលត្រូវបានរចនាឡើងសំរាប់ជនពិការ ដោយសារតែពួកគេពាក់ព័ន្ធទៅនឹងការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម ។

**មាត្រា ២៧ : ការងារ និងអាជីព**

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការក្នុងការមានការងារធ្វើ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។ សិទ្ធិនេះរួមទាំងសិទ្ធិមានឱកាសចិញ្ចឹមជីវិតដោយប្រកបការងារដែលគេអាចជ្រើសរើស ឬទទួលបានដោយសេរីលើទីផ្សារការងារ និងបរិយាកាសការងារដែលបើកចំហ មិនរើសអើង និងអាចឱ្យជនពិការធ្វើបាន ។ រដ្ឋភាគីត្រូវ ធានា និងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិការងារ រួមទាំងសំរាប់អ្នកទាំងឡាយដែលធ្លាក់ខ្លួនពិការ នៅពេលកំពុងបំពេញការងារ ដោយចាត់វិធានការសមស្រប រួមទាំងវិធានការតាមផ្លូវច្បាប់ដើម្បី :

ក- ហាមឃាត់ការរើសអើងដោយសារតែពិការភាព ចំពោះគ្រប់បញ្ហាដែលទាក់ទងនឹងរាល់ទំរង់នៃការងារ រួមទាំងលក្ខខណ្ឌនៃការជ្រើសរើស ការជួល និងបម្រើការងារ ការបន្តការងារ ការអភិវឌ្ឍន៍មុខរបរ និងលក្ខខណ្ឌ ការងារ ដែលមានសុវត្ថិភាព និងផាសុកភាព ។

ខ- ការពារសិទ្ធិជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ចំពោះលក្ខខណ្ឌការងារត្រឹមត្រូវ និងអនុគ្រោះ រួមទាំងឱកាសស្មើគ្នា និងប្រាក់កំរៃ

ស្មើគ្នា ចំពោះការងារដែលមានតំលៃស្មើគ្នា លក្ខខណ្ឌការងារដែលមានសុវត្ថិភាព និងផាសុកភាព រួមទាំងការការពារពីការយាយី និងការសងជំងឺចិត្ត ។

គ- ធានាថា ជនពិការអាចអនុវត្តសិទ្ធិបង្កើតសហជីព ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

ឃ- ឱ្យជនពិការអាចទទួលបានដោយប្រសិទ្ធភាព នូវកម្មវិធីណែនាំពីវិជ្ជាជីវៈ និងបច្ចេកទេសទូទៅ សេវាកម្ម រកការងារឱ្យធ្វើ និងការបណ្តុះបណ្តាលបន្តនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ង- បង្កើនឱកាសមានការងារធ្វើ និងការអភិវឌ្ឍន៍មុខរបរសម្រាប់ជនពិការនៅក្នុងទីផ្សារការងារ ក៏ដូចជាជំនួយក្នុងការស្វែងរក ការទទួលបាន ការរក្សា និងការវិលត្រឡប់ចូលបំរើការងារវិញ ។

ច- បង្កើនឱកាសដល់ជនពិការឱ្យមានមុខរបរផ្ទាល់ខ្លួន មានភាពជាសហគ្រិនបង្កើតអាជីវកម្មដែលអាច ចាប់ផ្តើមដោយខ្លួនឯង និងសហប្រតិបត្តិការ ។

ឆ- ផ្តល់ការងារដល់ជនពិការធ្វើក្នុងស្ថាប័នសាធារណៈ ។

ជ- បង្កើនការងារសម្រាប់ជនពិការក្នុងស្ថាប័នឯកជនតាមរយៈវិធានការ និងគោលនយោបាយសមស្របដែលអាចរួមមាន កម្មវិធីសកម្មភាពជាវិជ្ជមាន ការលើកទឹកចិត្ត និងវិធានការផ្សេងៗទៀត ។

ឈ- ធានាឱ្យមានដំណោះស្រាយសមស្របដល់ជនពិការនៅក្នុងកន្លែងធ្វើការ ។

ញ- បង្កើនលទ្ធភាពឱ្យជនពិការអាចទទួលបានបទពិសោធន៍ការងារនៅក្នុង

ទីផ្សារការងារសេរី ។

ង- ជំរុញការស្តារឡើងវិញផ្នែកជំនាញ និងវិជ្ជាជីវៈ ការរក្សាការងារ និង កម្មវិធីនានាដែលជួយឱ្យជនពិការ អាចត្រឡប់ចូលបំរើការងារវិញ ។

២- រដ្ឋភាគីត្រូវធានាថា ជនពិការមិនត្រូវធ្លាក់ទៅក្នុងភាពជាទាសករឬខ្ញុំកញ្ជះគេទេ ហើយត្រូវបានគេការពារ ពីការធ្វើពលកម្មដោយបង្ខំ ឬដោយមិនអាចប្រកែកបាន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ។

**មាត្រា ២៨ : ជីវភាពរស់នៅគ្រប់គ្រាន់ និងការការពារផ្នែកសង្គមកិច្ច**

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ពីជីវភាពរស់នៅគ្រប់គ្រាន់សម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់ក្រុមគ្រួសារ របស់ពួកគេ រួមទាំងការមានអាហារហូបចុកគ្រប់គ្រាន់ មានសំលៀកបំពាក់និងផ្ទះសំបែងសមរម្យ និងការកែលំអលក្ខខណ្ឌជីវភាពរស់នៅជាប្រចាំ ហើយរដ្ឋភាគីត្រូវចាត់វិធានការសមស្របដើម្បីការពារ និងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិនេះ ដោយគ្មានការរើសអើងដោយសារពិការភាពនោះទេ ។

២- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការពីការការពារផ្នែកសង្គមកិច្ច និងពីការទទួលបានសិទ្ធិនេះ ដោយគ្មាន ការរើសអើងដោយសារពិការភាព និងត្រូវចាត់វិធានការសមស្របដើម្បីការពារ និងលើកស្ទួយដល់ការធ្វើឱ្យបាន សម្រេចនូវសិទ្ធិនេះ រួមទាំងវិធានការដូចខាងក្រោម :

ក- ធានាដល់ជនពិការឱ្យទទួលបានដោយស្មើភាពគ្នានូវសេវាកម្មទឹកស្អាត

និងធានាដល់ជនពិការឱ្យទទួលបាននូវសេវាកម្ម គ្រឿងឧបករណ៍ និងជំនួយផ្សេងៗ ដែលសមស្រប និងមានតំលៃសមរម្យសម្រាប់បំរើសេចក្តីត្រូវ ការពាក់ពន្ធ័នឹងពិការភាព ។

ខ- ធានាដល់ជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងមនុស្សចាស់ពិការឱ្យទទួលបាននូវកម្មវិធីកាត់ បន្ថយភាពក្រីក្រ និងកម្មវិធីការពារផ្នែកសង្គមកិច្ច ។

គ- ធានាដល់ជនពិការ និងក្រុមគ្រួសាររបស់គេដែលកំពុងរស់នៅក្នុងស្ថាន-ភាពក្រីក្រ ឱ្យទទួលបាននូវជំនួយឧបត្ថម្ភពីរដ្ឋ តាមរយៈខ្ទង់ចំនាយលើផ្នែកពិការភាព រួមទាំងការបណ្តុះបណ្តាល ការផ្តល់ប្រឹក្សា ជំនួយហិរញ្ញវត្ថុ និងការថែទាំកំឡុងពេលសំរាកឱ្យបានគ្រប់គ្រាន់ ។

ឃ- ធានាដល់ជនពិការឱ្យទទួលបាននូវកម្មវិធីផ្ទះសំបែងសាធារណៈ ។

ង- ធានាដល់ជនពិការឱ្យទទួលបានដោយស្មើភាពគ្នានូវកម្មវិធី និងផលប្រយោជន៍សោធននិវត្តន៍ ។

**មាត្រា ២៩ : ការចូលរួមក្នុងជីវភាពនយោបាយ និងជីវភាពសាធារណៈ**

រដ្ឋភាគីត្រូវធានាដល់ជនពិការពីសិទ្ធិនយោបាយ និងឱកាសដែលជនពិការទទួលបានដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ និងត្រូវ :

ក- ធានាថា ជនពិការអាចចូលរួមដោយប្រសិទ្ធិភាព និងយ៉ាងពេញលេញក្នុងជីវភាពនយោបាយ និងជីវភាពសាធារណៈដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយសេរី ដោយឈរលើមូលដ្ឋានស្មើភាពគ្នា ជាមួយអ្នក

ដទៃ រួមទាំងសិទ្ធិ និងឱកាសសម្រាប់ជនពិការ ក្នុងការបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតដោយ :

i- ធានាថា នីតិវិធី ឧបករណ៍ និងសំភារៈបោះឆ្នោត មានលក្ខណៈសមស្រប អាចធ្វើទៅបានងាយយល់ និងងាយប្រើប្រាស់ ។

ii- ការពារសិទ្ធិរបស់ជនពិការ ក្នុងការបោះឆ្នោតដោយសំងាត់នៅក្នុងការបោះ-ឆ្នោត និងក្នុងការធ្វើប្រជាមតិជាសាធារណៈដោយគ្មានការបំភិតបំភ័យ និងក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោតដើម្បីចូលកាន់មុខតំណែង និងបំពេញគ្រប់មុខងារសាធារណៈឱ្យមានប្រសិទ្ធិភាពនៅគ្រប់ជាន់ថ្នាក់នៃស្ថាប័នរដ្ឋាភិបាល ដោយជួយសំរួលដល់ការប្រើប្រាស់បច្ចេកវិទ្យាជំនួយថ្មីៗដែលសមស្រប ។

iii- ធានាដល់ជនពិការនូវការសំដែងឆន្ទៈដោយសេរីជាអ្នកបោះឆ្នោត ហើយដើម្បីសម្រេចគោលដៅនេះ ក្នុងករណីចាំបាច់និងតាមសំណើរបស់ជនពិការ ត្រូវជួយពួកគេឱ្យបានបោះឆ្នោតជ្រើសរើសអ្នកណាម្នាក់តាមបំណងរបស់ខ្លួន ។

ខ- ជំរុញយ៉ាងសកម្មឱ្យមានបរិយាកាសមួយ ដែលជនពិការអាចចូលរួមយ៉ាងពេញលេញ និងប្រកបដោយ ប្រសិទ្ធិភាពក្នុងដំណើរការកិច្ចការសាធារណៈ ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ព្រមទាំងលើទឹក-ចិត្តឱ្យពួកគេចូលរួមក្នុងកិច្ចការសាធារណៈ រួមមាន :

i- ការចូលរួមក្នុងអង្គការក្រៅរដ្ឋាភិបាល និងសមាគមនានាដែលពាក់ព័ន្ធនឹងជីវភាពនយោបាយ និងជីវភាពសាធារណៈរបស់ប្រទេស និងក្នុងសកម្មភាព និងរដ្ឋបាលរបស់គណបក្សនយោបាយ ។

ii- ការបង្កើត និងការចូលរួមក្នុងអង្គការនានារបស់ជនពិការ ដើម្បីធ្វើជាអ្នកតំណាងជនពិការនៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅលើឆាកអន្តរជាតិ ។

**មាត្រា ៣០ : ការចូលរួមក្នុងជីវភាពវប្បធម៌ ការឈប់សម្រាក ការលំហែ និងកីឡា**

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ក្នុងការចូលរួមក្នុងជីវភាពវប្បធម៌ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា ជាមួយអ្នកដទៃ ហើយរដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របដើម្បីធានាថា ជនពិការ :

ក- មានសិទ្ធិទទួលបានសំភារៈវប្បធម៌តាមទំរង់ដែលគេអាចចូលរួមបាន ។

ខ- មានសិទ្ធិទទួលបានកម្មវិធីទូរទស្សន៍ ភាពយន្ត ល្ខោន និងសកម្មភាពវប្បធម៌ផ្សេងៗ ក្នុងទំរង់ដែលគេអាច ចូលរួមបាន ។

គ- មានសិទ្ធិចូលដល់ទីកន្លែងសម្រាប់ការសំដែង ឬសេវាកម្មវប្បធម៌ ដូចជារោងល្ខោន សារៈមន្ទីរ រោងភាពយន្ត បណ្ណាល័យ និងសេវាកម្មទេសចរណ៍ ព្រមទាំងតាមលទ្ធភាពដែលអាចធ្វើទៅបាន មានសិទ្ធិចូលដល់ បូជនីយស្ថាន និងរមណីយដ្ឋានសំខាន់ៗរបស់វប្បធម៌ជាតិ ។

២- រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានាដើម្បីឱ្យជនពិការអាចមានឱកាសអភិវឌ្ឍនិងប្រើប្រាស់សក្តានុពលខាងបញ្ញា សិល្បៈ និងគំនិតច្នៃប្រឌិតរបស់ខ្លួន មិនត្រឹមតែដើម្បីផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះទេ ថែមទាំង ដើម្បីភាពសំបូរបែបរបស់សង្គមទៀតផង ។

៣- រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប ដោយអនុលោមតាមច្បាប់អន្តរជាតិដើម្បីធានាថា ច្បាប់ទាំងឡាយដែលការពារកម្មសិទ្ធិបញ្ញា មិនបង្កឧបសគ្គដែលមិនសមហេតុផល ឬរើសអើងអ្វីឡើយដល់ជនពិការក្នុងការទទួលបានសំភារៈវប្បធម៌ ។

៤- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ជនពិការត្រូវមានសិទ្ធិ-បានការទទួលស្គាល់ និងការគាំទ្រនៃអត្តសញ្ញាណផ្នែកភាសា និងវប្បធម៌ជាក់លាក់របស់ខ្លួន រួមទាំងភាសាសញ្ញា និងវប្បធម៌មនុស្សថ្លង់ ។

៥- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ និងក្នុងទស្សនៈជួយឱ្យជនពិការអាចចូលរួមក្នុងសកម្មភាពនានា ផ្នែកកីឡា ការលំហែ និងការឈប់-សម្រាក រដ្ឋភាគីត្រូវចាត់វិធានការសមស្របផ្សេងៗដូចតទៅ ៖

ក- ជំរុញ និងលើកស្ទួយការចូលរួមរបស់ជនពិការឱ្យបានខ្លាំងក្លាតាមដែលអាចធ្វើទៅបាននៅក្នុងសកម្មភាពកីឡាជាសាធារណៈនៅគ្រប់កម្រិត ។

ខ- ធានាថា ជនពិការមានឱកាសរៀបចំ អភិវឌ្ឍ និងចូលរួមក្នុងសកម្មភាពកីឡា និងការឈប់សម្រាកជាក់ស្តែងសម្រាប់ជនពិការ ហើយដើម្បីសម្រេចបានគោលដៅនេះ ត្រូវលើកទឹកចិត្តឱ្យមានការផ្តល់ការណែនាំការបណ្តុះបណ្តាល និងធនធានសមស្របដោយផ្អែកលើគោលការណ៍ស្មើភាពគ្នាជាមួយអ្នកដទៃ ។

គ- ធានាថា ជនពិការអាចមានទីកន្លែងសម្រាប់លេងកីឡា ការឈប់សម្រាក និងទេសចរណ៍ ។

ឃ- ធានាថា កុមារពិការមានសិទ្ធិទទួលបានស្មើគ្នាជាមួយកុមារផ្សេងទៀត

ក្នុងការចូលរួមសកម្មភាពកីឡា ការលំហែ ការឈប់សម្រាក និងការសំដែង រួមទាំងសកម្មភាពទាំងឡាយនៅក្នុងប្រព័ន្ធសាលារៀនផង ។

ង- ធានាថា ជនពិការមានសិទ្ធិទទួលបានសេវាកម្មពីអ្នកទាំងឡាយដែលពាក់ព័ន្ធនឹងការរៀបចំសកម្មភាព កីឡា ការលំហែ ទេសចរណ៍ និងការឈប់សម្រាក ។

**មាត្រា ៣១ : ស្ថិតិ និងការប្រមូលទិន្នន័យ**

១- រដ្ឋភាគីទទួលខុសត្រូវប្រមូលព័ត៌មានសមស្រប រួមទាំងទិន្នន័យស្ថិតិ និងស្រាវជ្រាវដើម្បីឱ្យជនពិការអាចតាក់តែង និងអនុវត្តគោលនយោបាយ ដើម្បីធ្វើឱ្យអនុសញ្ញានេះមានប្រសិទ្ធភាព ។ ដំណើរការប្រមូល និងរក្សាព័ត៌មាន នេះត្រូវ :

ក- អនុលោមតាមវិធានការការពារដែលបានបង្កើតស្របច្បាប់ រួមទាំងច្បាប់ស្តីអំពីការការពារទិន្នន័យ ដើម្បីធានាការសំងាត់ និងការគោរពសិទ្ធិឯកជនរបស់ជនពិការ ។

ខ- អនុលោមតាមបទដ្ឋានដែលបានទទួលស្គាល់ជាអន្តរជាតិ ដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និង គោលការណ៍ក្រមសីលធមិក្នុងការប្រមូល និងការប្រើប្រាស់ស្ថិតិ ។

២- ព័ត៌មានដែលប្រមូលបានស្របតាមមាត្រានេះត្រូវបានបំបែក និងត្រូវបានប្រើប្រាស់តាមការសមស្របដើម្បីជួយ វាយតំលៃពីការអនុវត្តន៏កាតព្វកិច្ចរបស់រដ្ឋភាគីតាមអនុសញ្ញានេះ  និងដើម្បីកំណត់រកនិងដោះស្រាយឧបសគ្គនានា ដែលជនពិការជួបប្រទះក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ។

៣- រដ្ឋភាគីត្រូវសន្មត់ពីការទទួលខុសត្រូវចំពោះការផ្សព្វផ្សាយស្ថិតិទាំងនេះ និងធានាពីស្ថិតិទាំងនេះបានទៅដល់ដៃ ជនពិការ និងអ្នកដទៃទៀត ។

**មាត្រា ៣២ ៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ**

១- រដ្ឋភាគីទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការនេះ ក្នុងការគាំទ្រដល់ការខិតខំប្រឹងប្រែងថ្នាក់ជាតិ ចំពោះការធ្វើឱ្យបានសម្រេចនូវគោលបំណងនិងទិសដៅរបស់អនុសញ្ញានេះ ហើយនឹងចាត់វិធានការសមស្រប និងមានប្រសិទ្ធភាពចំពោះបញ្ហានេះរវាងនិងក្នុងចំណោមរដ្ឋ និងដៃគូជាមួយអង្គការអន្តរជាតិ និងតំបន់ដែលពាកព័ន្ធ និងសង្គមស៊ីវិល តាមការសមស្រប ជាពិសេសអង្គការជនពិការ ។ វិធានការបែបនេះអាចរួមមានដូចជា ៈ

ក- ការធានាថា កិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងកម្មវិធីអភិវឌ្ឍន៍អន្តរជាតិនានាត្រូវដាក់បញ្ចូលជនពិការ ហើយបានដល់ដៃជនពិការ ។

ខ- ការសម្របសម្រួល និងការគាំទ្រដល់ការកសាងសមត្ថភាព រួមទាំងតាមរយៈការផ្លាស់ប្តូរ និងការចែករំលែកព័ត៌មាន បទពិសោធន៍ កម្មវិធីបណ្តុះបណ្តាល និងការអនុវត្តល្អៗ ។

គ- ការសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវ និងការទទួលបានចំណេះដឹងបច្ចេកទេស និង វិទ្យាសាស្ត្រ ។

ឃ- ការផ្តល់ជំនួយសេដ្ឋកិច្ច និងបច្ចេកទេសតាមភាពសមស្រប រួមទាំង

តាមរយៈការជួយសម្រួលដល់ការទទួលបាន និងការចែករំលែកពីបច្ចេកវិទ្យាជំនួយ និងអាចទទួលយកបាន និងតាមរយៈការផ្ទេរបច្ចេកវិទ្យា ។

២- បទបញ្ញត្តិនៃមាត្រានេះមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគីនីមួយៗ ពីការបំពេញកាតព្វកិច្ចរបស់ខ្លួន តាមអនុសញ្ញានេះឡើយ ។

**មាត្រា ៣៣ : ការអនុវត្ត និងតាមដានត្រួតពិនិត្យថ្នាក់ជាតិ**

១- អនុលោមតាមប្រព័ន្ធនៃការរៀបចំរបស់ខ្លួន រដ្ឋភាគីត្រូវចាត់តាំងអ្នកសម្របសម្រួលម្នាក់ឬច្រើនក្នុងជួររដ្ឋាភិបាល សម្រាប់កិច្ចការដែលទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ ហើយត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវក្នុងការបង្កើត ឬការចាត់តាំងយន្តការសម្របសម្រួលមួយនៅក្នុងរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់សកម្មភាពដែលពាក់ព័ន្ធ ក្នុងវិស័យ និងនៅកម្រិតផ្សេងគ្នា ។

២- អនុលោមតាមប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធច្បាប់របស់ខ្លួន រដ្ឋភាគីត្រូវរក្សាពង្រឹង ចាត់តាំង ឬបង្កើតនូវក្របខណ្ឌមួយនៅក្នុងរដ្ឋភាគី រួមទាំងយន្តការឯករាជ្យមួយឬច្រើនតាមការសមស្រប ដើម្បីលើកស្ទួយការពារ និងតាមដាន ត្រួតពិនិត្យការអនុវត្តអនុសញ្ញានេះ ។
នៅពេលតែងតាំងឬបង្កើតយន្តការបែបនេះរដ្ឋភាគីត្រូវពិចារណាពីគោលការណ៍ដែលពាក់ព័ន្ធដល់ឋានៈ និងការប្រព្រឹត្តទៅរបស់ស្ថាប័នជាតិនានា ដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្ស ។

៣- សង្គមស៊ីវិល ជាពិសេសជនពិការ និងអង្គការតំណាងឱ្យជនពិការត្រូវពាក់ព័ន្ធ និងចូលរួមយ៉ាងពេញលេញក្នុង ដំណើរតាមដានត្រួតពិនិត្យ ។

**មាត្រា ៣៤ ៖ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ**

១- គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការមួយ (បន្ទាប់ពីនេះហៅថា ***គណៈកម្មាធិការ***) ត្រូវបានបង្កើតឡើងដែល ត្រូវបំពេញមុខនាទីដូចមានចែងនៅក្នុងមាត្រានេះ។

២- នៅពេលដែលអនុសញ្ញានេះចូលជាធរមាន គណៈកម្មាធិការនេះត្រូវមានអ្នកជំនាញការ១២រូប។ បន្ទាប់ពីមានការផ្តល់សច្ចាប័ណ្ណ ឬការចូលជាសមាជិកចំនួន៦០បន្ថែមទៀតលើអនុសញ្ញានេះ សមាជិកភាពរបស់គណៈកម្មាធិការនេះ ត្រូវបង្កើនសមាជិកចំនួន៦រូបទៀត តែទោះយ៉ាងណាត្រូវរក្សាចំនួនសមាជិកអតិបរមាត្រឹម១៨រូប។

៣- សមាជិកគណៈកម្មាធិការនេះត្រូវបំពេញការងារតាមសមត្ថភាពរៀងៗខ្លួន និងត្រូវមានសីលធម៌ខ្ពស់ ព្រមទាំងមានសមត្ថភាព និងបទពិសោធន៍ដែលត្រូវបានទទួលស្គាល់លើវិស័យដែលគ្របដណ្តប់ដោយអនុសញ្ញានេះ។ នៅពេលតែងតាំងបេក្ខភាពរបស់ខ្លួន រដ្ឋភាគីត្រូវបានអញ្ជើញឱ្យផ្តល់ការពិចារណាឱ្យបានត្រឹមត្រូវទៅលើបទបញ្ញត្តិដែលមានចែងនៅក្នុងមាត្រា៤ វាក្យខ័ណ្ឌ៣ នៃអនុសញ្ញានេះ។

៤- សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសរើសដោយការបោះឆ្នោត ដោយរដ្ឋភាគី ដោយឈរលើមូលដ្ឋាននៃការបែងចែកស្មើភាពតាមលក្ខណៈភូមិសាស្រ្ត ភាពតំណាងនៃទំរង់ផ្សេងៗរបស់អរិយធម៌ និងភាពតំណាងនៃប្រព័ន្ធច្បាប់ សំខាន់ៗ ត្រូវមានតុល្យភាពតំណាងយេនឌ័រ និងការចូលរួមពីអ្នកជំនាញការដែលជាជនពិការ។

៥- សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសដោយការបោះឆ្នោតជាសំងាត់ពី

បញ្ជីឈ្មោះបេក្ខជន ដែលត្រូវបានតែងតាំងដោយរដ្ឋភាគីពីចំនោមជនជាតិនៃរដ្ឋភាគីនោះ នៅឯកិច្ចប្រជុំនៃសន្និសិទរបស់រដ្ឋភាគី ។ ក្នុងកិច្ចប្រជុំទាំងនោះ កូរ៉ុមត្រូវកំណត់ចំនួនពីរភាគបីនៃរដ្ឋភាគី ហើយបេក្ខជនដែលត្រូវបានគេបោះឆ្នោតឱ្យចូលជាសមាជិកនៃគណៈកម្មាធិការនេះ គឺជាអ្នកដែលទទួលបានសំលេងឆ្នោតច្រើនជាងគេ និង ទទួលបានសំលេងភាគច្រើនដាច់ខាតពីតំណាងនៃរដ្ឋភាគី ដែលមានវត្តមានបោះឆ្នោត ។

៦- ការបោះឆ្នោតដំបូង ត្រូវធ្វើឡើងមិនឱ្យហួសរយៈពេល៦ខែ ក្រោយពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន ។ យ៉ាងហោច៤ខែមុនថ្ងៃបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ញើលិខិតទៅរដ្ឋភាគី ដើម្បីអញ្ជើញរដ្ឋទាំងនោះ ឱ្យដាក់សំណើតែងតាំងបេក្ខភាពរបស់ខ្លួនក្នុងរយៈពេលពីរខែ ។ បន្ទាប់មក អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីឈ្មោះតាមលំដាប់អក្ខរក្រមនៃបេក្ខជនទាំងអស់ដែលត្រូវបានតែងតាំង ដោយបញ្ជាក់ពីឈ្មោះរដ្ឋភាគីដែលបានតែងតាំងបេក្ខជនទាំងនោះផង ហើយត្រូវដាក់ជូនរដ្ឋភាគីនៃអនុសញ្ញានេះវិញ ។

៧- សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសតាំងសម្រាប់អណត្តិរយៈពេល ៤ឆ្នាំ ។ សមាជិកទាំងនេះ ត្រូវមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសាជាថ្មីបានតែម្តងប៉ុណ្ណោះ ។ ប៉ុន្តែអណត្តិរបស់សមាជិកចំនួន៦រូបនៃសមាជិកទាំងអស់ ដែលត្រូវបានជ្រើសរើសកាលពីការបោះឆ្នោតលើកទី១ ត្រូវផុតកំណត់នៅចុងបញ្ចប់នៃឆ្នាំទីពីរ ។ បន្ទាប់ពីការបោះឆ្នោត លើកទី១ភ្លាម ឈ្មោះរបស់សមាជិកទាំង៦រូបនេះត្រូវបាន

ចាប់ឆ្នោតជ្រើសរើសដោយប្រធាននៃកិច្ចប្រជុំ យោងតាមកថាខណ្ឌទី៥ នៃមាត្រានេះ ។

៨- ការបោះឆ្នោតជ្រើសរើសសមាជិក៦រូបបន្ថែម នៃគណៈកម្មាធិការនេះ ត្រូវធ្វើឡើងក្នុងឱកាសនៃការបោះឆ្នោតជា ទៀងទាត់ស្របទៅតាមបទបញ្ញត្តិពាក់ព័ន្ធ នៃមាត្រានេះ ។

៩- ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មាធិការនេះស្លាប់ ឬលាលែងពីតំណែង ឬប្រកាសថា គាត់មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានទៀតទេ ដោយសារមូលហេតុអ្វីក៏ដោយរដ្ឋភាគីដែលតែងតាំងសមាជិកនោះត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀតដែលមានគុណសម្បត្តិ និងបំពេញបានតាមលក្ខខណ្ឌដែលតម្រូវនៅក្នុងបទបញ្ញត្តិពាក់ព័ន្ធនៃមាត្រានេះដើម្បីបន្តបំពេញការងាររហូតដល់ចប់អណត្តិ ។

១០- គណៈកម្មាធិការត្រូវបង្កើតវិធាននីតិវិធរបស់ខ្លួន ។

១១- អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវផ្តល់បុគ្គលិក និងសំភារៈបរិក្ខារចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការ នេះបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពតាមអនុសញ្ញានេះ  ហើយត្រូវកោះប្រជុំលើកដំបូងរបស់គណៈកម្មាធិការ ។

១២- ដោយមានការអនុម័តយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ សមាជិកគណៈកម្មាធិការដែលត្រូវបាន បង្កើតឡើងតាមអនុសញ្ញានេះត្រូវទទួលបានប្រាក់ឧបត្ថម្ភពីប្រភពអង្គការសហប្រជាជាតិពីលក្ខខណ្ឌនិងខទាំងឡាយ ដូចដែលមហាសន្និបាតបានសម្រេច ដោយយល់ឃើញពីសារៈសំខាន់នៃការទទួលខុសត្រូវរបស់គណៈកម្មាធិការនេះ ។

១៣- សមាជិកគណៈកម្មាធិការត្រូវមានសិទ្ធិប្រើប្រាស់សំភារៈផ្សេងៗ មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាអ្នកជំនាញការដែលកំពុងបំពេញបេសកកម្ម ឱ្យអង្គការសហប្រជាជាតិ ដូចដែលមានចែងក្នុងប្រការពាក់ព័ន្ធទាំងឡាយនៃ សន្ធិសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ។

**មាត្រា ៣៥ : របាយការណ៍របស់រដ្ឋភាគី**

១- តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីនីមួយៗត្រូវដាក់ របាយការណ៍រួមស្តីពីការចាត់វិធានការណ៍នានាដើម្បីអនុវត្តកាតព្វកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពតាមអនុសញ្ញានេះ និងស្តីពីការវិវត្តដែលសម្រេចបាន លើកិច្ចការ ទាំងនេះក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ។

២- បន្ទាប់ពីនេះ រដ្ឋភាគីត្រូវដាក់របាយការណ៍បន្តបន្ទាប់របស់ខ្លួន យ៉ាងហោច ណាស់រៀងរាល់បួនឆ្នាំម្តង និងព័ត៌មានបន្ថែមទៀត នៅពេលណាដែល គណៈកម្មាធិការស្នើសុំ ។

៣- គណៈកម្មាធិការត្រូវសម្រេចពីគោលការណ៍ណែនាំដែលអាចអនុវត្តបាន ចំពោះមាតិកានៃរបាយការណ៍ ។

៤- រដ្ឋភាគីដែលបានដាក់របាយការណ៍រួមលើកដំបូងទៅគណៈកម្មាធិការ ពុំចាំបាច់លើកឡើងពីព័ត៌មានដដែលៗ ដែលបានផ្តល់កាលពីមុន នៅរបាយការណ៍ បន្តបន្ទាប់លើកក្រោយទៀតនោះទេ ។ នៅពេលរៀបចំធ្វើរបាយការណ៍ជូនគណៈ- កម្មាធិការ រដ្ឋភាគីត្រូវពិចារណាធ្វើកិច្ចការនេះ ក្នុងដំណើរការមួយដែលបើកចំហ និងមានតម្លាភាព និងត្រូវផ្តល់ការពិចារណាឱ្យបានត្រឹមត្រូវ ទៅតាមបទបញ្ញត្តិ

ដែលមានចែងក្នុងមាត្រា៤ វាក្យខ័ណ្ឌ៣នៃអនុសញ្ញានេះ ។

៥- របាយការណ៍អាចបង្ហាញពីកត្តាផ្សេងៗ និងការលំបាកនានា ដែលប៉ះពាល់ដល់កម្រិតនៃការបំពេញកាតព្វកិច្ចតាម អនុសញ្ញានេះ ។

**មាត្រា ៣៦ : ការពិនិត្យពិចារណាលើរបាយការណ៍**

១- របាយការណ៍នីមួយៗត្រូវបានពិនិត្យពិចារណាដោយគណៈកម្មាធិការ ដែលត្រូវធ្វើសំណូមពរ និងផ្តល់អនុសាសន៍ទូទៅដល់របាយការណ៍តាមដែលគណៈកម្មាធិ-ការយល់ឃើញថាសមស្រប រួចត្រូវបញ្ជូនសំណូមពរ និងអនុសាសន៍ ទាំងនេះទៅរដ្ឋភាគីសាម៉ីវិញ ។ រដ្ឋភាគីនោះអាចឆ្លើយតបជាមួយនឹងព័ត៌មានណាមួយ ដែលខ្លួនជ្រើសរើសទៅគណៈកម្មាធិការវិញ ។ គណៈកម្មាធិការអាចស្នើសុំព័ត៌មានបន្ថែមពីរដ្ឋភាគីដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញានេះ ។

២- ប្រសិនបើរដ្ឋភាគីមួយយឺតយ៉ាវខ្លាំងក្នុងការដាក់ជូនរបាយការណ៍ គណៈកម្មាធិការអាចជូនដំណឹងដល់រដ្ឋភាគីសាមី នោះអំពីសេចក្តីត្រូវការដើម្បីត្រួតពិនិត្យការអនុវត្តអនុសញ្ញានេះនៅក្នុងរដ្ឋភាគីនោះ ដោយឈរលើមូលដ្ឋានដែលគណៈកម្មាធិការមានព័ត៌មានគួរឱ្យទុកចិត្តបាន ប្រសិនបើរបាយការណ៍ពាក់ព័ន្ធមិនត្រូវបានប្រគល់ជូនក្នុងរយៈពេលបីខែបន្ទាប់ពីការជូនដំណឹង ។ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីសាមីឱ្យចូលរួមក្នុងការត្រួតពិនិត្យបែបនេះ ។ ប្រសិនបើរដ្ឋភាគីឆ្លើយតបដោយប្រគល់របាយការណ៍ពាក់ព័ន្ធ បទបញ្ញត្តិក្នុងកថាខណ្ឌទី១នៃមាត្រានេះនឹងត្រូវបានអនុវត្ត ។

៣- អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវចែករបាយការណ៍ទាំងនោះ

ដល់គ្រប់រដ្ឋភាគីទាំងអស់ ។

៤- រដ្ឋភាគីត្រូវផ្សព្វផ្សាយរបាយការណ៍របស់ខ្លួនឱ្យបានទូលំទូលាយ ដល់សាធារណៈជនក្នុងប្រទេសរបស់ខ្លួន ហើយជួយសំរួលដល់ការទទួលបានសំណូមពរ និងអនុសាសន៍ទូទៅដែលពាក់ព័ន្ធនឹងរបាយការណ៍នេះ ។

៥- គណៈកម្មាធិការត្រូវបញ្ជូនរបាយការណ៍ពីរដ្ឋភាគីតាមតែខ្លួនយល់ឃើញថាសមស្របទៅទីភ្នាក់ងារជំនាញ ស្ថាប័ន មូលនិធិ និងកម្មវិធីនានារបស់អង្គការសហប្រជាជាតិ និងអង្គភាពមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីស្នើសុំ ឬបញ្ជាក់ពីតម្រូវការលើផ្នែកប្រឹក្សា ឬជំនួយបច្ចេកទេស ដូចមាននៅក្នុងរបាយការណ៍ទាំងនោះ ដោយរួមជាមួយនឹងការសង្កេត ពិនិត្យ និងអនុសាសន៍របស់គណៈកម្មាធិការចំពោះសំណើ និងសេចក្តីបញ្ជាក់ទាំងនេះប្រសិនបើមាន ។

**មាត្រា ៣៧ : កិច្ចសហប្រតិបត្តិការ រវាងរដ្ឋភាគី និងគណៈកម្មាធិការ**

១- រដ្ឋភាគីនីមួយៗត្រូវធ្វើសហប្រតិបត្តិការជាមួយគណៈកម្មាធិការ និងជួយសមាជិកគណៈកម្មាធិការនេះក្នុងការ បំពេញការងារក្នុងអណត្តិរបស់ពួកគេ ។

២- ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋភាគី គណៈកម្មាធិការត្រូវគិតពិចារណាឱ្យបានត្រឹមត្រូវដល់វិធី និងមធ្យោបាយ នៃការលើកកម្ពស់សមត្ថភាពជាតិក្នុងការអនុវត្តអនុសញ្ញានេះ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣៨ : ទំនាក់ទំនងរបស់គណៈកម្មាធិការជាមួយស្ថាប័នផ្សេងៗទៀត**

ដើម្បីជំរុញឱ្យមានការអនុវត្តអនុសញ្ញានេះឱ្យមានប្រសិទ្ធភាព និងដើម្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការ អន្តរជាតិក្នុងវិស័យដូចមានចែងក្នុងអនុសញ្ញានេះ :

ក- ទីភ្នាក់ងារជំនាញ និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ត្រូវមានសិទ្ធិធ្វើជាអ្នកតំណាង ក្នុងការពិចារណាលើ ការអនុវត្តនៃបទបញ្ញត្តិរបស់អនុសញ្ញានេះ ដោយសារតែស្ថិតនៅក្នុងក្របខ័ណ្ឌអាណត្តិរបស់អង្គការទាំងនោះ ។ គណៈកម្មាធិ-ការ អាចកោះអញ្ជើញទីភ្នាក់ងារជំនាញ និងស្ថាប័នមានសមត្ថកិច្ចនានា តាមតែខ្លួនយល់ឃើញថាសមស្របដើម្បី ផ្តល់ប្រឹក្សាជំនាញពីការអនុវត្តអនុសញ្ញាក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួន ។ គណៈកម្មាធិការអាច កោះអញ្ជើញទីភ្នាក់ងារជំនាញ និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិដើម្បីប្រគល់របាយ-ការណ៍ស្តីពីការអនុវត្ត អនុសញ្ញាក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។

ខ- នៅពេលបំពេញអាណត្តិរបស់ខ្លួន គណៈកម្មាធិការត្រូវពិគ្រោះជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀតដែលបង្កើតឡើង ដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិតាមការសមស្រប ដើម្បីធានាពីភាពស៊ីសង្វាក់គ្នានៃគោលការណ៍ណែនាំសម្រាប់ធ្វើរបាយការណ៍នីមួយៗ សំណូមពរ និងអនុសាសន៍ទូទៅ និងដើម្បីជៀសវាងនូវភាពត្រួតគ្នា និងជាន់ភារកិច្ចគ្នាក្នុងការបំពេញមុខងារ ។

## មាត្រា ៣៩ : របាយការណ៍របស់គណៈកម្មាធិការ

គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ជារៀងរាល់ពីរឆ្នាំម្ដងជូនមហាសន្និបាត និងក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម របស់អង្គការសហប្រជាជាតិស្ដីពីសកម្មភាពរបស់ខ្លួន ហើយអាចធ្វើសំណូមពរ និងផ្ដល់អនុសាសន៍ទូទៅ ដោយផ្អែកលើការត្រួតពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី។ សំណូមពរ និងអនុសាសន៍ទូទៅទាំងនោះ ត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍របស់គណៈកម្មាធិការ រួមជាមួយនឹងមតិរបស់រដ្ឋភាគី ប្រសិនបើមាន។

## មាត្រា ៤០ : សន្និសីទរបស់រដ្ឋភាគី

១- រដ្ឋភាគីត្រូវជួបប្រជុំគ្នាជាទៀងទាត់ក្នុងសន្និសិទរបស់ខ្លួន ដើម្បីពិនិត្យពិចារណាលើបញ្ហាណាមួយទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ។

២- អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំសន្និសីទរបស់រដ្ឋភាគីមិនឱ្យហួសរយៈពេល៦ខែ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន។ កិច្ចប្រជុំជាបន្ត-បន្ទាប់ត្រូវបានកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ រៀងរាល់ពីរឆ្នាំម្ដង ឬតាមការសម្រេចរបស់សន្និសីទនៃរដ្ឋភាគី។

## មាត្រា ៤១ : អ្នកតម្កល់ទុកឯកសារ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវតែជាអ្នករក្សាទុកអនុសញ្ញានេះ។

**មាត្រា ៤២ ៖ ការចុះហត្ថលេខា**

អនុសញ្ញានេះត្រូវបើកចំហដល់រដ្ឋទាំងអស់ និងអង្គការសមាហរណកម្មនានាថ្នាក់តំបន់ចុះហត្ថលេខានៅឯទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧។

**មាត្រា ៤៣ ៖ សេចក្តីយល់ព្រមអនុវត្តន៍**

អនុសញ្ញានេះត្រូវតែជាកម្មវត្ថុនៃការផ្តល់សច្ចាប័នដោយរដ្ឋហត្ថលេខី ហើយជាកម្មវត្ថុនៃការបញ្ជាក់ជាផ្លូវការ ដោយអង្គការសមាហរណកម្មនានា ថ្នាក់តំបន់ដែលជាហត្ថលេខី។ អនុសញ្ញានេះត្រូវបើកចំហចំពោះការចូលជាសមាជិក ដោយរដ្ឋឬអង្គការសមាហរណកម្មតំបន់ ដែលមិនបានចុះហត្ថលេខាលើអនុសញ្ញានេះ។

**មាត្រា ៤៤ ៖ អង្គការសមាហរណកម្មនានាថ្នាក់តំបន់**

១- "អង្គការសមាហរណកម្មតំបន់ " មានន័យថាជាអង្គការដែលបង្កើតឡើងដោយរដ្ឋដែលមានអធិបតេយ្យភាពនៃតំបន់ណាមួយ ដែលរដ្ឋជាសមាជិកនៅក្នុងតំបន់នោះបានប្រគល់សមត្ថកិច្ចឱ្យដោះស្រាយបញ្ហានានាដែលគ្រប់គ្រង ដោយអនុសញ្ញានេះ។ អង្គការទាំងនេះត្រូវប្រកាសនៅក្នុងលិខិតុបករណ៍នៃការបញ្ជាក់ជាផ្លូវការឬការចូលជាសមាជិករបស់ខ្លួនអំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ក្នុងការដោះស្រាយបញ្ហានានា ដែលគ្រប់គ្រងដោយអនុសញ្ញានេះ។ បន្ទាប់មកអង្គការទាំងនោះ ត្រូវជូនដំណឹងដល់អ្នកតម្កល់ទុកឯកសារពីការកែប្រែខសំខាន់ៗណាមួយនៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន។

២- បទបញ្ញត្តិទាំងឡាយដែលនិយាយយោងដល់ "រដ្ឋភាគី " នៅក្នុងអនុសញ្ញានេះត្រូវអនុវត្តចំពោះអង្គការទាំងនេះ នៅក្នុងព្រំដែននៃសមត្ថកិច្ចរបស់ខ្លួន។

៣- ចំពោះគោលបំណងនៃមាត្រា៤៥ កថាខ័ណ្ឌទី១ និងមាត្រា៤៧ កថាខ័ណ្ឌទី២ និងទី៣នៃអនុសញ្ញានេះ លិខិតុបករណ៍ណាក៏ដោយ ដែលត្រូវតម្កល់ទុកដោយអង្គការសមាហរណកម្មថ្នាក់តំបន់មួយមិនត្រូវបានរាប់បញ្ចូលទេ។

៤- ចំពោះបញ្ហាស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មថ្នាក់តំបន់អាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីបោះឆ្នោតនៅឯសន្និសីទនៃរដ្ឋភាគី ដោយមានចំនួនសន្លឹកឆ្នោតស្មើនឹងចំនួននៃប្រទេសជាសមាជិករបស់អង្គការនេះ ដែលជាភាគីនៃអនុសញ្ញា។ អង្គការនេះមិនអាចប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួនបានទេ ប្រសិនបើប្រទេសជាសមាជិករបស់ខ្លួន ប្រើសិទ្ធិបោះឆ្នោតនោះហើយ ឬបញ្ច្រាស់គ្នាមកវិញ។

**មាត្រា ៤៥ : ការចូលជាធរមាន**

១- អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីមានការតម្កល់ទុកលិខិតុបករណ៍ចំនួន២០នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក។

២- ចំពោះរដ្ឋ ឬអង្គការសមាហរណកម្មថ្នាក់តំបន់នីមួយៗដែលនឹងផ្តល់សច្ចាប័ន ការបញ្ជាក់ជាផ្លូវការ ឬការចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍ចំនួន២០នោះ អនុសញ្ញានេះត្រូវចូលជាធរ មាននៅ៣០ថ្ងៃចំពោះរដ្ឋនោះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍របស់ខ្លួន។

**មាត្រា ៤៦ ៖ ការដាក់លក្ខខណ្ឌ**

១- ការដាក់លក្ខខណ្ឌដែលមិនស្របនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតិឡើយ ។

២- ការដាក់លក្ខខណ្ឌដូចខាងលើនេះ អាចត្រូវបានដកវិញនៅពេលណាក៏បាន ។

**មាត្រា ៤៧ ៖ ការធ្វើវិសោធនកម្ម**

១- រដ្ឋភាគីណាក៏ដោយអាចស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះបាន រួចដាក់សំណើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវជូនព័ត៌មានស្តីពីសំណើធ្វើវិសោធនកម្មទាំងឡាយទៅរដ្ឋភាគីដោយស្នើសុំឱ្យរដ្ឋទាំងនោះបញ្ជាក់ថាតើ ខ្លួនគាំទ្រឱ្យមានសន្និសីទនៃរដ្ឋភាគីចំពោះគោលបំណងនៃការពិចារណា និងការសម្រេចលើសំណើទាំងនោះឬអត់ ។ ក្នុងរយៈពេល៤ខែគិតចាប់ពីថ្ងៃ ដែលជូនដំណឹងនោះមក ក្នុងករណីដែលរដ្ឋភាគីយ៉ាងតិចមួយភាគបីគាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទនេះក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ ការធ្វើវិសោធនកម្មណាមួយដែលអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃរដ្ឋភាគី ដែលមានវត្តមានបោះឆ្នោត ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិដាក់ជូនមហាសន្និបាតអង្គការសហប្រជា ជាតិសម្រាប់ការអនុម័តយល់ព្រម រួចហើយជូនទៅគ្រប់រដ្ឋភាគីសម្រាប់ការទទួលយល់ព្រម ។

២- ការធ្វើវិសោធនកម្មដែលបានយល់ព្រម និងអនុម័ត អនុលោមទៅតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ត្រូវចូល ជាធរមាននៅថ្ងៃទី៣០បន្ទាប់ពីមានចំនួន

លិខិតុបករណ៍នៃការទទួលយល់ព្រមត្រូវបានតម្កល់ទុកឡើងដល់ពីរភាគបីនៃរដ្ឋភាគី នាឱកាសនៃការអនុម័តវិសោធនកម្មនេះ ។ បន្ទាប់មក វិសោធនកម្មនេះត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីណាក៏ដោយនៅថ្ងៃទី៣០ក្រោយពីការតម្កល់ទុកលិខិតុបករណ៍នៃការទទួលយល់ព្រមរបស់ខ្លួន ។ វិសោធនកម្មអនុវត្តបានតែចំពោះរដ្ឋភាគីណាដែលបានទទួលយល់ព្រមលើការធ្វើវិសោធនកម្ម នោះតែប៉ុណ្ណោះ ។

៣- ប្រសិនបើការធ្វើវិសោធនកម្មនេះ ត្រូវបានសម្រេចដោយសន្និសីទនៃរដ្ឋ-ភាគី ដោយការយល់ព្រមជាឯកច្ឆ័ន្ទ ការធ្វើវិសោធនកម្មដែលបានយល់ព្រមនិងអនុម័តដោយអនុលោមតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ដែល ពាក់ព័ន្ធទាំងស្រុងទៅនឹងមាត្រា ៣៤, ៣៨, ៣៩ និង ៤០ ត្រូវចូលជាធរមានសម្រាប់គ្រប់រដ្ឋភាគី នៅថ្ងៃទី៣០បន្ទាប់ពីមានចំនួនលិខិតុបករណ៍នៃការទទួលយល់ព្រមត្រូវបានតម្កល់ទុកឡើងដល់ពីរភាគបីនៃរដ្ឋភាគី នាឱកាសនៃការអនុម័តវិសោធនកម្មនេះ ។

## មាត្រា ៤៨ : ការដកខ្លួនចេញពីអនុសញ្ញា

រដ្ឋភាគីមួយអាចដកខ្លួនចេញពីអនុសញ្ញានេះបាន ដោយជូនដំណឹងជាលាយ-ល័ក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការដកខ្លួននេះត្រូវមានប្រសិទ្ធភាពនៅ១ឆ្នាំក្រោយ បន្ទាប់ពីថ្ងៃដែលអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបានសេចក្តីជូនដំណឹងនោះ ។

## មាត្រា ៤៩ : លក្ខណៈងាយស្រួលប្រើប្រាស់

អត្ថបទនៃអនុសញ្ញានេះត្រូវតែធ្វើឡើងក្នុងទំរង់ដែលមានលក្ខណៈងាយស្រួលប្រើប្រាស់ ។

**មាត្រា ៥០ : អត្ថបទដើម**

អត្ថបទដើមនៃអនុសញ្ញានេះ មានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា។

# ពិធីសារបន្ថែមលើអនុសញ្ញា ស្ដីពី សិទ្ធិជនពិការ

**រដ្ឋភាគីនៃពិធីសារនេះបានព្រមព្រៀងគ្នាដូចតទៅ :**

**មាត្រា ១ :**

១- រដ្ឋភាគីនៃពិធីសារនេះ "រដ្ឋភាគី " ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិជនពិការ "គណៈកម្មាធិការ " ក្នុងការទទួលនិងពិនិត្យបណ្ដឹងដែលធ្វើដោយបុគ្គលឬក្នុងនាមបុគ្គល ឬក្រុមបុគ្គលដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋភាគីដែលបុគ្គលនោះអះអាងថា ជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើបទបញ្ញត្តិនៃអនុសញ្ញានេះ ។

២- គណៈកម្មាធិការមិនទទួលបណ្ដឹងមកពិនិត្យទេ ប្រសិនបើបណ្ដឹងនោះពាក់ព័ន្ធនឹងរដ្ឋភាគីនៃអនុសញ្ញា ដែលមិនមែនជាភាគីនៃពិធីសារនេះ ។

**មាត្រា ២ :**

គណៈកម្មាធិការមិនអាចទទួលដោះស្រាយរាល់បណ្ដឹងក្រោមពិធីសារនេះទេប្រសិនជា :

ក- បណ្ដឹងអនាមិក

ខ- បណ្ដឹងរំលោភសិទ្ធិដាក់ពាក្យបណ្ដឹង ឬមានវិសមិត្តភាពនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។

គ- បញ្ហាដដែលនេះ ត្រូវបានគណៈកម្មាធិការពិនិត្យរួចហើយ ឬត្រូវបាន និង

កំពុងពិនិត្យ ស្របតាមនីតិវិធីនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ។

ឃ- មិនទាន់បានប្រើប្រាស់អស់ដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក។ គេមិនអាចទទួលយកបានទេ ប្រសិនបើការប្រើប្រាស់ដំណោះស្រាយនេះបានអូសបន្លាយរយៈពេលយូរហួសហេតុ ឬមិនទំនងជានាំមកនូវការជួយឱ្យធូរស្បើយយ៉ាងមានប្រសិទ្ធភាពទេនោះ។

ង- មិនបានបញ្ជាក់មូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើជាអំណះអំណាង ឬ

ច- នៅពេលដែលអង្គហេតុជាកម្មវត្ថុនៃបណ្តឹងបានកើតមាន នៅមុនថ្ងៃចូលជាធរមាននៃពិធីសារនេះសម្រាប់រដ្ឋភាគីពាក់ព័ន្ធ បើពុំនោះទេ លុះត្រាតែអង្គហេតុនោះ បានបន្តរហូតដល់ក្រោយកាលបរិច្ឆេទនៃពិធីសារនេះ។

**មាត្រា ៣ ៖**

ស្របតាមបទបញ្ញត្តិមាត្រា២នៃពិធីសារនេះគណៈកម្មាធិការត្រូវផ្តល់ដំណឹងជាសំងាត់ដល់រដ្ឋភាគីពាក់ព័ន្ធអំពី បណ្តឹងដែលបានបញ្ជូនមកឱ្យខ្លួន។ ក្នុងរយៈពេល៦ខែ រដ្ឋចុងចំលើយត្រូវបញ្ជូនការពន្យល់ជាលាយល័ក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយរបស់រដ្ឋនោះទៅគណៈកម្មាធិការប្រសិនជាមាន។

**មាត្រា ៤ ៖**

១- នៅគ្រប់ពេល បន្ទាប់ពីការទទួលបណ្តឹង និងនៅមុនពេលឈានដល់ការសម្រេចលើអង្គសេចក្តី គណៈកម្មាធិការអាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីពិនិត្យជាបន្ទាន់លើសំណើដែលរដ្ឋភាគីចាត់វិធានការបណ្តោះអាសន្ន តាមការចាំបាច់ ដើម្បីជៀសវាងការអាចកើតមាននូវការគេចវេសមិនជួសជុលសំណងការខូចខាតដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ដែលអះអាងថាបានទទួលរងការរំលោភ ។

២- ប្រសិនបើគណៈកម្មាធិការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនស្របតាមកថាខ័ណ្ឌទី១នៃមាត្រានេះ នោះមិន ានបញ្ជាក់ថា ជាការសម្រេចទទួលយក ឬការសម្រេចលើអង្គសេចក្តីនៃបណ្តឹងឡើយ ។

**មាត្រា ៥ ៖**

គណៈកម្មាធិការត្រូវប្រជុំជាសំងាត់នៅពេលពិនិត្យបណ្តឹងទាំងឡាយស្របតាមពិធីសារនេះ ។ បន្ទាប់ពីពិនិត្យបណ្តឹងរួច គណៈកម្មាធិការត្រូវបញ្ជូនការយល់ឃើញអំពីបណ្តឹងនោះ រួមជាមួយអនុសាសន៍របស់ខ្លួនប្រសិនជាមាន ទៅរដ្ឋភាគីពាក់ព័ន្ធ និងទៅអ្នកប្តឹងទាមទារ ។

**មាត្រា ៦ ៖**

១- ប្រសិនបើគណៈកម្មាធិការទទួលព័ត៌មានគួរឱ្យទុកចិត្តដែលបង្ហាញឱ្យឃើញពីការរំលោភធ្ងន់ធ្ងរឬជាប្រព័ន្ធ ដោយរដ្ឋភាគីទៅលើសិទ្ធិទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញានេះ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីនោះឱ្យសហការពិនិត្យព័ត៌មាន

និងផ្តល់សេចក្តីសង្កេតចំពោះព័ត៌មានពាក់ព័ន្ធ ។

២- តាមការពិនិត្យសេចក្តីសង្កេតដែលរដ្ឋភាគីពាក់ព័ន្ធបញ្ជូនមករួមមានព័ត៌មានពាក់ព័ន្ធសមស្របផ្សេងទៀតផង គណៈកម្មាធិការអាចចាត់តាំងសមាជិកម្នាក់ ឬច្រើននាក់ឱ្យស៊ើបអង្កេត និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ ។ ប្រសិនជាចាំបាច់ និងដោយមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបអង្កេតនេះអាចរួមទាំងការធ្វើទស្សនកិច្ចទៅកាន់ទឹកដីនៃរដ្ឋនោះ ។

៣- ក្រោយពីការពិនិត្យសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេតនេះ គណៈកម្មា-ធិការត្រូវបញ្ជូនសេចក្តីសន្និដ្ឋាន ទាំងនេះទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ឬអនុសាសន៍ ។

៤- រដ្ឋភាគីពាក់ព័ន្ធត្រូវបញ្ជូនសេចក្តីសង្កេតរបស់ខ្លួនទៅគណៈកម្មាធិការក្នុងរយៈពេល៦ខែនៃការទទួលសេចក្តីសន្និដ្ឋាន ការផ្តល់យោបល់ និងអនុសាសន៍ដែលគណៈកម្មាធិការបានបញ្ជូនមក ។

៥- ការស៊ើបអង្កេតនេះត្រូវធ្វើជាសំងាត់ និងត្រូវស្វែងរកកិច្ចសហការពីរដ្ឋភាគីនៅគ្រប់ដំណាក់កាលនៃកិច្ច ដំណើរការនេះ ។

**មាត្រា ៧ :**

១- គណៈកម្មាធិការអាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធ ឱ្យផ្តល់ព័ត៌មានបន្ថែមទៅក្នុងរបាយការណ៍របស់ខ្លួន ស្របតាមមាត្រា៣៥ នៃអនុសញ្ញានេះ ដោយបញ្ជាក់ច្បាស់អំពីវិធានការនានាដែលបានចាត់ឡើង ឆ្លើយតបទៅនឹងការស៊ើបអង្កេតដែលបាន

ធ្វើឡើងតាមមាត្រា៦នៃពិធីសារនេះ។

២- ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានឱ្យខ្លួនអំពីវិធានការទាំងឡាយដែលបានចាត់ឡើង ឆ្លើយតបទៅនឹងការស៊ើប-អង្កេតនេះ បន្ទាប់ពីផុតរយៈពេល៦ខែដូចមានចែងក្នុងមាត្រា៦ កថាខ័ណ្ឌទី៤នៃពិធីសារនេះ។

**មាត្រា ៨ :**

រដ្ឋភាគីនីមួយៗអាចប្រកាសនៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះថា ខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការនេះ ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ ឡើយ។

**មាត្រា ៩ :**

អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាអ្នកទទួលរក្សាទុកពិធីសារនេះ។

**មាត្រា ១០ :**

ពិធីសារនេះ បើកចំហដល់រដ្ឋហត្ថលេខី និងអង្គការសមាហរណកម្មថ្នាក់តំបន់នៃអនុសញ្ញានេះចុះហត្ថលេខា នៅទីស្នាក់ការអង្គការសហប្រជាជាតិក្នុងទីក្រុងញូវយ៉ក ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ តទៅ។

**មាត្រា ១១ :**

ពិធីសារនេះត្រូវជាកម្មវត្ថុនៃការឱ្យសច្ចាប័នដោយរដ្ឋហត្ថលេខីនៃពិធីសារនេះ

ដែលបានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិកនៃអនុសញ្ញានេះ ។ ពិធីសារនេះត្រូវជាកម្មវត្ថុនៃការបញ្ជាក់ជាផ្លូវការ ដោយអង្គការសមាហរណកម្ម ថ្នាក់តំបន់ដែលជាហត្ថលេខីនៃពិធីសារនេះ ដែលបានបញ្ជាក់ជាផ្លូវការ ឬបានចូលជាសមាជិកនៃអនុស-ញ្ញានេះ ។ ពិធីសារនេះបើកចំហសម្រាប់ការចូលជាសមាជិកដោយរដ្ឋ ឬអង្គការសមា-ហរណកម្មថ្នាក់តំបន់ណាមួយ ដែលបានផ្តល់សច្ចាប័ន បានបញ្ជាក់ជាផ្លូវការឬបានចូលជាសមាជិកនៃអនុសញ្ញានេះ ហើយដែលមិនទាន់បានចុះហត្ថលេខាលើពិធីសារនេះ ។

**មាត្រា ១២ :**

១- "អង្គការសមាហរណកម្មតំបន់ " គឺជាអង្គការមួយដែលត្រូវបានបង្កើតឡើង ដោយរដ្ឋអធិបតេយ្យទាំងឡាយនៃតំបន់ណាមួយជាក់លាក់ដែលរដ្ឋសមាជិកទាំងអស់បានផ្ទេរសមត្ថកិច្ចក្នុងក្របខ័ណ្ឌនៃអនុសញ្ញា និងពិធីសារនេះ ។ អង្គការទាំងនេះត្រូវប្រកាសក្នុងលិខិតុបករណ៍នៃការបញ្ជាក់ ឬការចូលជាសមាជិកផ្លូវការអំពីដែនសមត្ថកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានិងពិធីសារនេះ ។ បន្ទាប់មក អង្គការទាំងនោះត្រូវជូនដំណឹងទៅប័ណ្ណសារដ្ឋានអង្គការសហប្រជាជាតិអំពីការកែប្រែ ខ្លឹមសារណាមួយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

២- បញ្ញត្តិដែលចែងពី "រដ្ឋភាគី" នៅក្នុងពិធីសារនេះត្រូវអនុវត្តចំពោះអង្គការទាំងនេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៣- សម្រាប់គោលបំណងនៃមាត្រា១៣ កថាខ័ណ្ឌទី១ និងមាត្រា១៥ កថាខ័ណ្ឌទី២នៃពិធីសារនេះ លិខិតុបករណ៍ណាមួយដែលបានតម្កល់ដោយអង្គការសមាហរណកម្មតំបន់មួយ មិនត្រូវបានធ្វើការពិចារណាឡើយ ។

៤- អង្គការសមាហរណកម្មតំបន់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អាចប្រើប្រាស់សិទ្ធិបោះឆ្នោតនៅក្នុងការប្រជុំ រដ្ឋភាគី ចំនួនសន្លឹកឆ្នោតត្រូវស្មើនឹងចំនួនរដ្ឋសមាជិកដែលជាភាគីនៃអនុសញ្ញានេះ។ អង្គការនេះ មិនអាចប្រើសិទ្ធិបោះឆ្នោតបានទេប្រសិនបើរដ្ឋសមាជិករបស់ខ្លួនណាមួយប្រើសិទ្ធិនេះរួចហើយ ឬបញ្ច្រាស់គ្នាមកវិញ។

**មាត្រា ១៣ :**

១- ស្របតាមការចូលជាធរមាននៃអនុសញ្ញានេះ ពិធីសារនេះត្រូវចូលជាធរមាននៅថ្ងៃទី៣០បន្ទាប់ពីកាល បរិច្ឆេទនៃការតម្កល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី១០។

២- ចំពោះរដ្ឋ ឬអង្គការសមាហរណកម្មនីមួយៗ ដែលឱ្យសច្ចាប័នលើពិធីសារនេះ បញ្ជាក់ជាផ្លូវការ ឬចូលជាសមាជិកនៃពិធីសារនេះ ក្រោយពីការតម្កល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលសមាជិកទី១០ ហើយ ពិធីសារនេះត្រូវចូលជាធរមាននៅថ្ងៃទី៣០បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនីមួយៗ ដាក់តម្កល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬ លិខិតុបករណ៍ចូលសមាជិករបស់ខ្លួន។

**មាត្រា ១៤ :**

១- លក្ខខ័ណ្ឌដែលវិសមិត្តភាពជាមួយគោលដៅនិងគោលបំណងនៃពិធីសារនេះ មិនត្រូវបានអនុញ្ញាតឡើយ។

២- ការដាក់លក្ខខណ្ឌ អាចត្រូវបានដកចេញគ្រប់ពេលវេលា។

**មាត្រា ១៥ ៖**

១- រដ្ឋភាគីនៃពិធីសារនេះអាចស្នើសុំធ្វើវិសោធនកម្មពិធីសារនេះ និងដាក់ជូនទៅអគ្គលេខាធិការអង្គការ សហប្រជាជាតិ។ អគ្គលេខាធិការត្រូវបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធនកម្មនេះទៅរដ្ឋភាគីនៃពិធីសារនេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ប្រាប់មកអគ្គលេខាធិការវិញថា តើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគី ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំធ្វើវិសោធនកម្មឬទេ។ ក្នុងរយៈពេល៤ខែ គិតពីកាលបរិច្ឆេទនៃការជូនព័ត៌មានទៅរដ្ឋភាគី បើមាន សម្លេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានកិច្ចប្រជុំនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតនៅឯកិច្ចប្រជុំត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ហើយបន្ទាប់មក ត្រូវបញ្ជូនទៅរដ្ឋភាគីទាំងអស់ ដើម្បីសុំការទទួលយក។

២- វិសោធនកម្មដែលបានអនុម័ត និងយល់ព្រមស្របតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ចូលជាធរមាននៅ៣០ថ្ងៃ បន្ទាប់ពីចំនួនលិខិតុបករណ៍នៃការទទួលយកបានតម្កល់គ្រប់ចំនួន២ភាគ៣នៃចំនួនរដ្ឋភាគី នៅកាលបរិច្ឆេទនៃការ អនុម័តវិសោធនកម្មនេះ។ បន្ទាប់មក វិសោធនកម្មត្រូវចូលជាធរមាននៅថ្ងៃទី៣០បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនោះ តម្កល់លិខិតុបករណ៍នៃការទទួលយករបស់ខ្លួន។ វិសោធនកម្មនេះនឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីទាំងឡាយដែលយល់ព្រមទទួលយក។